# ឧបសម្ព័ន្ធ ក ៖ សារណារបស់ អៀង សារី

# ស្ដីពីច្បាប់ជាធរមានដែលអាចអនុវត្ត

# បាននៅក្នុងសំណុំរឿង ០០២/០១

# សារណារបស់ អៀង សារី ស្តីពីច្បាប់ជាធរមានដែលត្រូវអនុវត្តនៅក្នុងសំណុំរឿង ០០២/០១
## មាតិការឿង


I. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ: ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក - មាត្រា ៥ ....3

ក. លក្ខខណ្ឌតម្រូវ*ទូទៅ* .... 3

១. អំពើដែលជាដើមចម គឺជា "ផ្នែកមួយនៃ" ការវាយប្រហារ (ចំណងទាក់ទងគ្នា) .... 3

២. លក្ខណៈជាទូទៅ ឬជាប្រព័ន្ធ .... 4

៣. ការវាយប្រហារ .... 4

៤. សំដៅប្រឆាំងទៅលើប្រជាជនស៊ីវិល .... 5

៥. មូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា .... 5

៦. លក្ខខណ្ឌកំណត់ដែលថា ការវាយប្រហារកើតឡើងស្របតាមគោលនយោបាយរបស់រដ្ឋ ឬតាមផែនការចាត់តាំង អនុលោមតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ .... 5

៧. លក្ខខណ្ឌកំណត់ថា ការវាយប្រហារមានចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធ អនុលោមតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងឆ្នាំ ១៩៧៥-១៩៧៩ .... 11

៨. ការដឹងឮ .... 15

ខ. បទល្មើសជាដើមចម .... 15

១. ការធ្វើមនុស្សឃាត .... 15

២. ការសម្លាប់រង្គាល .... 15

៣. ការធ្វើទុក្ខបុកម្នេញ (ដោយមូលហេតុនយោបាយ និងពូជសាសន៍) .... 17

៤. ការផ្លាស់ប្តូរទីកន្លែងដោយបង្ខំ .... 17

៥. ការបាត់ខ្លួនបុគ្គលដោយបង្ខំ .... 19

៦. អំពើអមនុស្សធម៌ផ្សេងៗទៀត .... 21

II. ទម្រង់នៃការទទួលខុសត្រូវ ÷ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ÷ មាត្រា ២៩ ....23

ក. ការរៀបចំផែនការ ........ 23

ខ. ការញុះញង់ ........ 24

គ. ការបញ្ជា ........ 24

ឃ. ការជួយ និងទំនុកបម្រុង ........ 24

ង. ការប្រព្រឹត្ត ........ 25

ច. សហឧក្រិដ្ឋកម្មរួម ........ 25

១. អត្ថិភាពនៃសហឧក្រិដ្ឋកម្មរួម អនុលោមតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩26

២. ធាតុផ្សំនៃទម្រង់មូលដ្ឋាននៃសហឧក្រិដ្ឋកម្មរួម (JCE I) និងទម្រង់ជាប្រព័ន្ធ នៃ សហឧក្រិដ្ឋកម្មរួម (JCE II) ........ 28

ឆ. ការទទួលខុសត្រូវរបស់អ្នកបញ្ជា ........ 29

១. អត្ថិភាពនៃការទទួលខុសត្រូវរបស់អ្នកបញ្ជាក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងឆ្នាំ ១៩៧៥-៧៩. 30

២. ធាតុផ្សំនៃការទទួលខុសត្រូវរបស់អ្នកបញ្ជា ........ 35

# ច្បាប់ជាធរមាន

## I. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ: ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក - មាត្រា ៥

1. ដើម្បីចាត់ទុកអំពើមួយថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ លក្ខខណ្ឌតម្រូវបរិបទមួយចំនួន (ដែលត្រូវបានគេលើកឡើងជាទូទៅថាជា លក្ខខណ្ឌតម្រូវ *ទូទៅ* (chapeau) ឬតាមលក្ខខណ្ឌយុត្តាធិការ) ត្រូវតែបំពេញជាមុនសិន[1]។ មាត្រា ៥ កំណត់លក្ខខណ្ឌថា: (១) អំពើដែលរងការចោទប្រកាន់ត្រូវតែជា "ផ្នែកមួយ" (២) ការវាយប្រហារ (៣) ដែលមានលក្ខណៈជាទូទៅ *ឬ* ជាប្រព័ន្ធ។ (៤) ប្រឆាំងទៅលើប្រជាជនស៊ីវិល (៥) ដោយមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយ[2]។ នៅចន្លោះឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ច្បាប់ទំនៀមទម្លាប់អន្តរជាតិបានកំណត់បន្ថែមទៀតថា ការវាយ ប្រហារកើតឡើងស្របតាមគោលនយោបាយរបស់រដ្ឋ ឬតាមផែនការចាត់តាំង[3] និងមានទំនាក់ទំនង ជាមួយនឹងជម្លោះប្រដាប់អាវុធ[4]។

### ក. លក្ខខណ្ឌតម្រូវ *ទូទៅ*

#### ១. អំពើដែលជាដើមចម គឺជា "ផ្នែកមួយនៃ" ការវាយប្រហារ (ចំណងទាក់ទងគ្នា)

---

[1] អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ឃើញថា៖ "មាត្រា ៥ មិនត្រឹមតែកំណត់អត្ថន័យនៃអំពើជាមូលដ្ឋានដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិប៉ុណ្ណោះទេ ថែមទាំងគូសបញ្ជាក់ពីលក្ខខណ្ឌ ទៅតាមបរិបទដែលត្រូវតែស្វែងរកឲ្យឃើញថា កើតមានដើម្បីញែកឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិចេញពីឧក្រិដ្ឋកម្មតាមច្បាប់ជាតិ និងឧក្រិដ្ឋកម្មអន្តរជាតិផ្សេងៗទៀត"។ រឿងក្តី កាំង ហ្កេកអ៊ាវ ហៅ ឌុច សំណុំរឿង ០០១/១៨-០៧-២០០៧/អវតក/អជតក សាលដីកា ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ("សាលដីកាលើរឿងក្តី *ឌុច*") កថាខណ្ឌ ១០៦។ នៅក្នុងរឿងក្តី *Tadić* អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ("ICTY") បានពណ៌នាអំពីលក្ខខណ្ឌកំណត់ *ទូទៅ* ថាជា "លក្ខខណ្ឌនៃភាពអាចអនុវត្តបាននៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ដែលត្រូវបង្ហាញឲ្យឃើញថា ជនជាប់ចោទបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានចោទប្រកាន់ណាមួយបន្ថែមពីលើធាតុផ្សំជាក់លាក់នៃបទល្មើសដែលបានគូសបញ្ជាក់។ រឿងក្តី រដ្ឋអាជ្ញា ទល់នឹង *Tadić* IT-94-1-T សាលក្រម ចុះថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ១៩៩៧ កថាខណ្ឌ ៦២៥។ លក្ខខណ្ឌកំណត់ ទូទៅ "ត្រូវតែមានគេជឿជាក់មុនពេលបទល្មើសដែលបានគូសបញ្ជាក់បង្កើតបាននូវឧក្រិដ្ឋកម្មនៃសារៈសំខាន់ជាអន្តរជាតិ"។ GIDEON BOAS ET AL., បណ្ណាល័យអ្នកប្រកបវិជ្ជាជីវៈច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ កម្រិត I: ទម្រង់នៃការទទួលខុសត្រូវនៅក្នុងច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ (CUP 2007) ("BOAS")។

[2] ច្បាប់ស្តីពីការបង្កើត អវតក មាត្រា ៥។ សាលដីកាលើរឿងក្តី *ឌុច* កថាខណ្ឌ ១០៦។

[3] *សូមមើល* ខាងក្រោម កថាខណ្ឌ ៧ ដល់ ១០។

[4] *សូមមើល* ខាងក្រោម កថាខណ្ឌ ១១ ដល់ ១២។

2. អំពើទាំងឡាយរបស់ជនជាប់ចោទ តាមលក្ខណៈ ឬតាមផលវិបាករបស់វា ជាក់ស្តែងត្រូវតែជាផ្នែកមួយនៃការវាយប្រហារ[5]។ អំពើណាមួយដែលត្រូវបានប្រព្រឹត្តមុនពេល ក្រោយពេល ឬនៅទីកន្លែងឆ្ងាយពីទីកន្លែងដែលមានការវាយប្រហារ នៅតែអាចជាផ្នែកមួយនៃការវាយប្រហារ ប្រសិនបើមានការពាក់ព័ន្ធគ្រប់គ្រាន់ទៅនឹងការវាយប្រហារ[6]។

### ២. លក្ខណៈជាទូទៅ ឬជាប្រព័ន្ធ

3. ការវាយប្រហារត្រូវតែមានលក្ខណៈជាទូទៅ *ឬ* ជាប្រព័ន្ធ[7]។ ពាក្យថា "លក្ខណៈជាទូទៅ" គឺ សំដៅទៅលើការវាយប្រហារដែលមានលក្ខណៈទូលំទូលាយ និងមានចំនួនជនរងគ្រោះច្រើន[8]។ ពាក្យថា "ជាប្រព័ន្ធ" គឺសំដៅទៅលើអំពើហិង្សាដែលមានការរៀបចំ និងដែលអំពើនោះមិនអាចកើតមានឡើងដោយចៃដន្យនោះទេ[9]។

### ៣. ការវាយប្រហារ

4. ការវាយប្រហារគឺជាការប្រព្រឹត្តនូវអំពើហិង្សាច្រើនលើប្រជាជនស៊ីវិល[10]។ ការវាយប្រហារអាចកើត មានឡើងមុន អាចអូសបន្លាយពេលយូរ ឬបន្តមានរហូតក្នុងអំឡុងពេលនៃជម្លោះប្រដាប់អាវុធ[11]។

---

[5] សាលក្រមលើរឿងក្តី *ឌុច* កថាខណ្ឌ ៣១៨។

[6] *ដូចយោងខាងលើ។* ឧក្រិដ្ឋកម្មត្រូវតែជាអំពើដាច់ចេញពីគេ ដូចជា ដកចេញមកពីការវាយប្រហារដែលអំពើនោះមិនអាចលើកឡើងដោយសមហេតុផលបានទេថាគឺជាផ្នែកមួយនៃការវាយប្រហារ ដោយពិចារណាលើបរិបទ និងកាលៈទេសៈទាំងឡាយដែលអំពើត្រូវបានប្រព្រឹត្ត។ *ដូចយោងខាងលើ។*

[7] *ដូចយោងខាងលើ។* កថាខណ្ឌ ៣០០ ដល់ ៣០១ ដើម្បីវាយតម្លៃថាតើការវាយប្រហារមានលក្ខណៈជាទូទៅ ឬជាលក្ខណៈប្រព័ន្ធ អង្គជំនុំជម្រះសាលាដំបូងត្រូវ: (១) កំណត់អត្តសញ្ញាណប្រជាជនដែលជាកម្មវត្ថុនៃការវាយប្រហារ។ និង (២) ពិនិត្យលើមធ្យោបាយ វិធីសាស្ត្រ ធនធាន និងលទ្ធផលនៃការវាយប្រហារទៅលើប្រជាជន។ អង្គជំនុំជម្រះសាលាដំបូងអាចធ្វើការពិចារណាអំពីផលវិបាកដែលកើតចេញពីការវាយប្រហារទៅលើប្រជាជនដែលបានកំណត់ថាជាគោលដៅ មានចំនួនជនរងគ្រោះច្រើន លក្ខណៈនៃអំពើទាំងនោះ លទ្ធភាពនៃការចូលរួមរបស់មន្ត្រី ឬអាជ្ញាធរ ឬគំរូនៃឧក្រិដ្ឋកម្មផ្សេងទៀតដែលអាចកត់សម្គាល់បាន ដើម្បីកំណត់ថាតើការវាយប្រហារមានលក្ខណៈ ជាទូទៅ ឬជាប្រព័ន្ធ ឬ ការវាយប្រហារនោះមានលក្ខណាទាំងពីរ។ *ដូចយោងខាងលើ*។ *សូមមើលផងដែរ* រឿងក្តី រដ្ឋអាជ្ញា ទល់នឹង *Kunarac et al.*, IT-96-23 & IT-96-23/1-A សាលដីកា ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០២ ("សាលដីកាលើរឿងក្តី *Kunarac*") កថាខណ្ឌ ៩៥។

[8] សាលក្រមលើរឿងក្តី *ឌុច* កថាខណ្ឌ ៣០០។

[9] *ដូចយោងខាងលើ*។

[10] *ដូចយោងខាងលើ* កថាខណ្ឌ ២៩៨។

[11] *ដូចយោងខាងលើ* កថាខណ្ឌ ២៩៩។។

### ៤. សំដៅប្រឆាំងទៅលើប្រជាជនស៊ីវិល

5. ប្រជាជន "ស៊ីវិលច្រើនលើសលុប" ត្រូវតែជា "គោលដៅចំបងនៃការវាយប្រហារ"[12]។ ប្រសិនបើប្រជាជនស៊ីវិលគ្រាន់តែជាគោលដៅបន្ទាប់បន្សំ ការវាយប្រហារមិនមែនជាការ "សំដៅប្រឆាំង" លើប្រជាជនស៊ីវិលនោះទេ[13]។ សមាជិកនៃកងកម្លាំងប្រដាប់អាវុធ និងអ្នកប្រយុទ្ធផ្សេងទៀត[14] ទាហានដែលបាត់បង់សមត្ថភាពក្នុងការប្រយុទ្ធ[15] និងអ្នករួមចំណែកផ្ទាល់នៅក្នុងការបង្កអរិយភាព[16] មិនត្រូវបានចាត់ទុកថាជាជនស៊ីវិលទេ។

### ៥. មូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា

6. ការវាយប្រហារដែលមានលក្ខណៈជាទូទៅ ឬជាប្រព័ន្ធ សំដៅប្រឆាំងទៅលើប្រជាជនស៊ីវិល ត្រូវតែបានប្រព្រឹត្តដោយមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយ[17]។

### ៦. លក្ខខណ្ឌកំណត់ដែលថា ការវាយប្រហារកើតឡើងស្របតាមគោលនយោបាយរបស់រដ្ឋ ឬតាមផែនការចាត់តាំង អនុលោមតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩

---

[12] *ដូចយោងខាងលើ* កថាខណ្ឌ ៣០២, ៣០៥, ៣០៨។

[13] សាលដីកាលើរឿងក្តី *Kunarac* កថាខណ្ឌ ៩២។ *សូមមើល* សាលក្រមលើរឿងក្តី *ឌុច* កថាខណ្ឌ ៣០៥, ៣០៩ សម្រាប់កត្តាទាំងឡាយដែលពាក់ព័ន្ធទៅនឹងការកំណត់ថា តើការវាយប្រហារ "សំដៅផ្ទាល់" លើប្រជាជនស៊ីវិល ឬយ៉ាងណា។

[14] សាលក្រមលើរឿងក្តី *ឌុច* កថាខណ្ឌ ៣០៤។ សូមមើលផងដែរ ពិធីសារបន្ថែមលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ និងពាក់ព័ន្ធទៅនឹងការការពារជនរងគ្រោះដោយសារជម្លោះប្រដាប់អាវុធអន្តរជាតិ ចុះថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ១៩៧៧ ("ពិធីសារបន្ថែម I") មាត្រា ៥០។ អនុសញ្ញា (III) ទាក់ទិនទៅនឹងការព្យាបាលឈ្លើយសឹក ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ មាត្រា ៤ក។ រឿងក្តី រដ្ឋអាជ្ញា ទល់នឹង *Blaškić* IT-95-14-A សាលដីកា ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៤ ("សាលដីកាលើរឿងក្តី *Blaškić*") កថាខណ្ឌ ១១២ ដល់ ១១៣។ រឿងក្តី រដ្ឋអាជ្ញា ទល់នឹង *Sesay et al.*, SCSL-04-15-T សាលក្រម ចុះថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០០៩ ("សាលដីកាលើរឿងក្តី *Sesay*") កថាខណ្ឌ ៨២។ រឿងក្តី រដ្ឋអាជ្ញា ទល់នឹង *Bemba Gombo*, ICC-01/05-01/08-424 សេចក្តីសម្រេចអនុលោមតាមមាត្រា ៦១(៧)(ក) និង(ខ) នៃច្បាប់លក្ខន្តិកៈទីក្រុងរ៉ូមស្តីពីការចោទប្រកាន់របស់រដ្ឋអាជ្ញាលើ Jean-Pierre Bemba Gombo ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៩ កថាខណ្ឌ ៧៨។

[15] សាលក្រមលើរឿងក្តី *ឌុច* កថាខណ្ឌ ៣០៤។

[16] សាលដីកាលើរឿងក្តី *Sesay* កថាខណ្ឌ ៨៦។ *សូមមើល* រឿងក្តី រដ្ឋអាជ្ញា ទល់នឹង *Fofana et al.*, SCSL-04-14-A សាលដីកា ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៨ កថាខណ្ឌ ២៦០។

[17] *សូមមើល* ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៥។ សាលក្រមលើរឿងក្តី *ឌុច* កថាខណ្ឌ ៣១៣។

7. ទោះបីជាមិនចែងច្បាស់លាស់នៅក្នុងមាត្រា ៥ ក៏ដោយ នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ បានកំណត់លក្ខខណ្ឌថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវប្រព្រឹត្តឡើងស្របតាមគោលនយោបាយរបស់រដ្ឋ ឬតាមផែនការចាត់តាំង[18]។ អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅពេល អង្គជំនុំជម្រះលើកឡើងទាំងស្រុងថា អត្ថិភាពនៃគោលនយោបាយ ឬផែនការមិនមែនជាធាតុផ្សំចាំបាច់នៃឧក្រិដ្ឋកម្មនោះទេ[19]។

8. ធម្មនុញ្ញ[20] និងសាលក្រម[21] របស់តុលាការយោធាអន្តរជាតិនៅប្រទេស Nuremberg (“IMT”) បានតម្រូវថា ការវាយប្រហារត្រូវតែប្រព្រឹត្តឡើងជាផ្នែកមួយនៃគោលនយោបាយរបស់រដ្ឋ ឬតាមផែនការចាត់តាំង[22]។ មាត្រា ៦ នៃធម្មនុញ្ញតុលាការយោធា IMT បានផ្តល់យុត្តាធិការរបស់តុលាការយោធា IMT ឱ្យ

[18] *សូមមើល* ញត្តិជាជម្រើសស្តីពីការកំហិតលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ កថាខណ្ឌ ១០។ បណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ កថាខណ្ឌ ១៩០។

[19] សាលក្រមលើរឿងក្តី *ឌុច* កថាខណ្ឌ ៣០១។ “ទោះបីជាអត្ថិភាពនៃគោលនយោបាយ ឬផែនការអាចជាភ័ស្តុតាងមួយទាក់ទងនឹងការបង្កើតឱ្យមាននូវការវាយប្រហារដែលមានលក្ខណៈជាទូទៅ ឬជាប្រព័ន្ធក៏ដោយ ក៏អត្ថិភាពនៃគោលនយោបាយ និងផែនការទាំងនោះមិនមែនជាធាតុផ្សំចាំបាច់នៃឧក្រិដ្ឋកម្មនោះទេ”។

[20] ធម្មនុញ្ញរបស់តុលាការយោធានៅ Nuremberg, 82 U.N.T.S. 279 ចុះថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៩៤៥ មាត្រា ៦(គ)។

[21] សាលក្រមរបស់តុលាការយោធា IMT សម្រាប់ការជំនុំជម្រះរឿងក្តីឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗអាល្លឺម៉ង់ Nuremberg ចុះថ្ងៃទី ៣០ ខែ កញ្ញា និងថ្ងៃទី ១ ខែ តុលា ឆ្នាំ ១៩៤៦ London H.S.S.O. Miscellaneous លេខ ១២( ឆ្នាំ ១៩៤៦) (“សាលក្រមតុលាការយោធា IMT”)។

[22] *សូមមើល ដូចយោងខាងលើ* កថាខណ្ឌ ២៥៤ យោងទៅលើ “គោលនយោបាយនៃភេរវកម្ម” និង “គោលនយោបាយនៃការធ្វើទុក្ខបុកម្នេញ ការគាបសង្កត់ និងការសម្លាប់ជនស៊ីវិល”។ សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញាសាធារណៈ ទល់នឹង *Menten* ប្រទេសហូឡង់ តុលាការ District Court of Amsterdam អង្គជំនុំជម្រះព្រហ្មទណ្ឌវិសាមញ្ញ បោះពុម្ពផ្សាយឡើងវិញនៅក្នុង 75 INT'L L. REP. 362-63 (ឆ្នាំ ១៩៨១)៖ “ទស្សនាទាននៃ “ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ” ក៏តម្រូវផងដែរ... ថា ឧក្រិដ្ឋកម្មដែលបាន លើកឡើងត្រូវបង្កើតជាផ្នែកមួយនៃប្រព័ន្ធមួយដែលមានមូលដ្ឋានលើភេរវកម្ម ឬបង្កើតជាទំនាក់ទំនងមួយនៅក្នុងគោលនយោបាយ ដែលប្រព្រឹត្តឡើងដោយបានដឹងជាមុនដែលសំដៅផ្ទាល់លើប្រជាជនក្រុមណាមួយជាក់លាក់”។ M. CHERIF BASSIOUNI ឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិនៅក្នុងច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ ២៧៧ (Kluwer 1999) (“BASSIOUNI ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ”)៖ “សកម្មភាព ឬគោលនយោបាយរបស់រដ្ឋ” គឺជាចរិតលក្ខណៈសំខាន់នៃ “ឧក្រិដ្ឋកម្មប្រឆាំង មនុស្សជាតិ”។ M. CHERIF BASSIOUNI & PETER MANIKAS ច្បាប់របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ៥៤៨ (បោះពុម្ពផ្សាយឆ្លងដែន ឆ្នាំ ១៩៩៦)៖ “ការបញ្ចូលនូវការធ្វើទុក្ខបុកម្នេញជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលចែងដាច់ដោយ ឡែកនៅក្នុងលក្ខន្តិកៈរបស់តុលាការ ICTY “បញ្ជាក់ពីការដកលក្ខខណ្ឌកំណត់ក្រោមមាត្រា ៦(គ) នៃធម្មនុញ្ញតុលាការយោធា IMT ដែលថា ការធ្វើទុក្ខបុកម្នេញបែបនេះបង្កើតបានជាគោលនយោបាយនៃការធ្វើទុក្ខបុកម្នេញ”។

"ផ្តន្ទាទោស និងដាក់ទោសលើជនទាំងឡាយណាដែលបានប្រព្រឹត្តអំពើណាមួយដែលមាននៅក្នុងច្បាប់ចែង មិនថាជាបុគ្គល ឬជាសមាជិកនៃអង្គការឡើយ ដោយដើរតួនាទីដើម្បីប្រយោជន៍របស់ប្រទេសសម្ព័ន្ធមិត្តអឺរ៉ុប"[23]។ ធម្មនុញ្ញ IMT បានកំណត់ថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានប្រព្រឹត្តឡើង "ដោយទាក់ទងជាមួយនឹងឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការ"[24] ដែល "ចងភ្ជាប់ [ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ] ទៅនឹងឧក្រិដ្ឋកម្មទាំងឡាយដែលទាក់ទិនជាមួយនឹងផែនការ ឬគោលនយោបាយរបស់រដ្ឋ ពោលគឺ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព"[25]។

9. នៅក្នុងឆ្នាំ ២០០២ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃសាលាក្តី ICTY បានលុបចោលដោយមានកំហុសនូវលក្ខខណ្ឌនៃគោលនយោបាយអង្គការ ឬ រដ្ឋចេញពីក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[26]។

---

[23] ធម្មនុញ្ញតុលាការយោធា IMT មាត្រា ៦ បុព្វកថា (សេចក្តីបញ្ជាក់បន្ថែម)។

[24] *ដូចយោងខាងលើ* មាត្រា ៦(គ)។

[25] M. CHERIF BASSIOUNI ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ: បដិវត្តន៍ជាប្រវត្តិសាស្ត្រ និងពាក្យសុំនាបច្ចុប្បន្ន 3 (CUP 2011) ("BASSIOUNI ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ: បដិវត្តន៍ជាប្រវត្តិសាស្ត្រ")។

[26] សាលដីកាលើរឿងក្តី *Kunarac* កថាខណ្ឌ ៩៨។ សាស្ត្រាចារ្យ Bassiouni សង្កេតឃើញថា៖ "[សេចក្តីសម្រេច] នេះគួរឱ្យសោកស្តាយដោយសារហេតុផលមួយចំនួន។ ក្រោយពីបានអនុម័ត ច្បាប់លក្ខន្តិកៈរបស់តុលាការ ICTY មានគោលបំណងផ្ទុះបញ្ចាំងច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលមានអត្ថិភាពនៅពេលនោះ...។ ធាតុផ្សំនៃគោលនយោបាយរដ្ឋគឺជាធាតុផ្សំនៃ[ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ] ចាប់តាំងពីពេលអនុវត្តនៅតុលាការយោធា IMT។ គ្មានការវិវឌ្ឍណាមួយក្រោយពេលអនុម័តធម្មនុញ្ញបានលុបចោលលក្ខខណ្ឌនេះឡើយ ទោះបីជាយុត្តិសាស្ត្រ និងច្បាប់ជាតិខ្លះស្តីពី [ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ] បានតម្កល់លក្ខខណ្ឌនេះក៏ដោយ។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះសាលាឧទ្ធរណ៍មិនបានពិចារណាទាំងស្រុងតែម្តងលើមាត្រា ៧ នៃច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម និងសេចក្តីអត្ថាធិប្បាយនានា ដែលបានតម្កល់លក្ខខណ្ឌមួយនេះផងដែរ។ ក៏ប៉ុន្តែ អង្គជំនុំជម្រះសាលាឧទ្ធរណ៍គ្រាន់តែមិនធ្វើការពិចារណាលើឯកសារមូលដ្ឋានទាំងនេះតែប៉ុណ្ណោះ។ ផ្ទុយមកវិញ នៅក្នុងលេខយោងជើងទំព័រ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានជ្រើសរើសលើកឡើងអំពីទស្សនៈយល់ឃើញរបស់ខ្លួនអំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ ទៅតាមរឿងក្តីដែលខ្លួនពេញចិត្តដែលពុំមែនជាមូលដ្ឋានគាំទ្រការអះអាងរបស់ខ្លួននោះទេក្រោយពីបានពិនិត្យបន្ថែម"។ Bassiouni, Crimes Against Humanity: Historical Evolution 25-26, 28។ សាស្ត្រាចារ្យ Schabas បានយល់ស្របថា៖ "ការពិភាក្សាសង្ខេបរបស់តុលាការ ICTY អំពីបញ្ហាផែនការ ឬ គោលនយោបាយរដ្ឋពាក់ព័ន្ធនឹង...ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ...មានលក្ខណៈស្មាក់ស្មើរមិនលម្អិត។ លទ្ធផលសម្រេចបាន ពោលគឺ ផែនការ ឬ គោលនយោបាយរដ្ឋ ពុំមែនជាលក្ខខណ្ឌទាមទារមួយនោះទេ ទំនងជាសេចក្តីសម្រេចនយោបាយផ្តោតសំខាន់លើលទ្ធផល ពុំមែនជាការវិភាគលម្អិតអំពីប្រវត្តិនៃ[ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ] ឬ ការវិភាគផ្អែកតាមទ្រឹស្តីនោះទេ។ តុលាការ ICTY ក៏ទំនងជាពុំបានពិចារណាលើសេចក្តីព្រាងអំពីប្រវត្តិនេះផងដែរ...ហើយនិងការវិវឌ្ឍនាពេលក្រោយៗមកទៀត ដូចជា ការងាររបស់គណៈកម្មការនីតិកម្មអន្តរជាតិ ជាដើម"។ William A. Schabas, *State Policy as an Element of International Crimes,* 98 J. Crim. & Criminology 953, 959-60 (ឆ្នាំ ២០០៨) ("Schabas")។

សាលដីកាលើរឿងក្តី *Kunarac* ត្រូវបានសម្រេច*ក្រោយ* យុត្តាធិការតាមពេលវេលារបស់ អ.វ.ត.ក ហើយប្រភពភាគច្រើន ដែលត្រូវបានដកស្រង់ជាភ័ស្តុតាងនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិក៏កើតក្រោយយុត្តាធិការតាមពេលវេលារបស់ អ.វ.ត.ក ជាង ១៥ ឆ្នាំដែរ[27]។ ទោះបីជាសាលដីកានេះពុំមែនជាភ័ស្តុតាងនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៩ ក៏ដោយ ក្រុមមេធាវីការពារក្តីនឹងពិនិត្យសេចក្តីសម្រេចនេះ ពីព្រោះសាលដីកានេះត្រូវបានដកស្រង់ជាមូលដ្ឋាន នៅក្នុងសាលដីកានាពេលក្រោយៗ[28]។

10. អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានដកស្រង់ប្រភពចំនួន ១៦ ដែលអង្គជំនុំជម្រះនេះបានលើកឡើងថា ប្រភពទាំងនេះ "*បានគាំទ្រច្រើនលើសលប់*" លើសេចក្តីសម្រេចរបស់ខ្លួន[29]។ ផ្ទុយមកវិញ *គ្មាន*ប្រភពណាមួយបានផ្តល់*ការគាំទ្រយ៉ាងច្រើនលើសលប់*នោះទេ ពោលគឺ ប្រភពក្នុងនោះចំនួន ១០ ដែលត្រូវ បានដកស្រង់*ពុំបាន*គាំទ្រយ៉ាងជាក់លាក់ចំពោះការលុបចោលលក្ខខណ្ឌ នៃគោលនយោបាយនោះទេ[30]។ ប្រភពចំនួន ៥

---

[27] ប្រភព ១០ ក្នុងចំណោមប្រភពទាំង ១៦ ត្រូវបានដកស្រង់ចេញពីកិច្ចពិភាក្សាដេញដោលនៃអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៅក្នុងឆ្នាំ ១៩៩១។

[28] *សូមមើល ឧ.* រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* Kordić & Čerkez IT-95-14/2-A សាលដីកា ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៤ ("សាលដីកាKordić & Čerkez") កថាខណ្ឌ ៩៨។ ១០ ក្នុងចំណោមប្រភពទាំង ១៦ ត្រូវបានដកស្រង់ចេញពីកិច្ចពិភាក្សាដេញដោលនៃអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៅក្នុងឆ្នាំ ១៩៩១។ សាលដីកា *Blaškic* កថាខណ្ឌ ១២០។ *រដ្ឋអាជ្ញា ទល់នឹង Kajelijeli* ICTR-98-44-A-T សាលក្រម ចុះថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០០៣ កថាខណ្ឌ ៨៧២។ សាលក្រម *Sesay* កថាខណ្ឌ ៧៨-៧៩។

[29] សាលដីកា *Kunarac* កថាខណ្ឌ ៩៨ កំណត់សម្គាល់លេខ ១១៥។

[30] ១. ច្បាប់លេខ ១០ នៃក្រុមប្រឹក្សាត្រួតពិនិត្យ ដែលរួមបញ្ចូលលក្ខខណ្ឌស្តីពីគោលនយោបាយរបស់រដ្ឋ ឬតាមផែនការចាត់តាំងពុំត្រូវបានអនុវត្តដោយតុលាការអន្តរជាតិដែលអនុវត្តច្បាប់អន្តរជាតិឡើយ។ ច្បាប់លេខ ១០ ត្រូវបានអនុវត្តដោយតុលាការសម្ព័ន្ធមិត្តអាល្លឺម៉ង់ "តុលាការក្នុងស្រុកដែលលើកឡើងច្បាប់ក្នុងស្រុកចំបងៗ រួមបញ្ចូលបទប្បញ្ញត្តិទាំងឡាយដែលកើតចេញពីអាជ្ញាធរកាន់កាប់"។ Egon Schwelb, *Crimes Against Humanity*, 23, Brit. Y.B. Int'l L. 178, 218 (1946) ("Schwelb")។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង សភាអូស្ត្រាលី និងប្រទេសមួយទៀត* (១៩៩១) ១៧២ CLR ៥០១ (ថ្ងៃទី ១៤ សីហា ឆ្នាំ ១៩៩៤) មតិយោបល់របស់ចៅក្រម Toohey កថាខណ្ឌ ៥៩។ **២.** រឿងក្តី *Polyukhovich ទល់នឹង ប្រទេសអូស្ត្រាលី* ពាក់ព័ន្ធនឹងករណីថាតើប្រទេសអូស្ត្រាលីអាចចោទប្រកាន់ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សចោទដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃសង្គ្រាមលោកលើកទីពីរ។ *Polyukhovich ទល់នឹង ប្រទេសអូស្ត្រាលី និងប្រទេសមួយទៀត* (១៩៩១) ១៧២ CLR ៥០១ (ថ្ងៃទី ១៤ សីហា ឆ្នាំ ១៩៩៤)។ តុលាការបានទទួលយកនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងធម្មនុញ្ញនៃសាលាក្តី IMT ដែលទាមទារលក្ខខណ្ឌថា អំពើណាដែលបង្កើតជាឧក្រិដ្ឋកម្មសង្គ្រាម ឬ ដែលត្រូវបានប្រព្រឹត្តឡើងពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មសង្គ្រាម (ដែលជាប់ពាក់ព័ន្ធនឹងគោលនយោបាយរដ្ឋ)។ *សូមមើល ដូចខាងលើ* មតិយោបល់របស់ចៅក្រម Toohey កថាខណ្ឌ ៦៩-៧១។ ជាទូទៅ ករណីនេះត្រូវបានយល់ឃើញថាជាការគាំទ្រលក្ខខណ្ឌនៃគោលនយោបាយអង្គការ ឬ រដ្ឋ នៅក្នុងឧក្រិដ្ឋកម្មប្រឆាំង

មនុស្សជាតិ។ Shane Darcy & Joseph Powderly, Judicial Creativity at the International Criminal Tribunal 91 (OUP 2010) ("Darcy & Powderly")។ Robert Cryer និងជនផ្សេងទៀត, An Introduction to International Criminal Law and Procedure 238 (បោះពុម្ពផ្សាយលើកទីពីរ CUP 2010) ("Cryer")។ **៣.** រឿងក្តី *A.G. ប្រទេសអ៊ីស្រាអែល ទល់នឹង* Eichmann ត្រូវបានផ្អែកទាំងស្រុងលើផែនការ ឬ គោលនយោបាយណាហ្វី។ ចៅក្រមបានសន្និដ្ឋានថា *Eichmann* បានដឹង "ផែនការសម្ងាត់ក្នុងការសម្លាប់រង្គាល" ចាប់តាំងពីពាក់កណ្តាលឆ្នាំ ១៩៤១។ រឿងក្តី *A.G. ប្រទេសអ៊ីស្រាអែល ទល់នឹង* Eichmann ៣៦ I.L.R. 5 (Jer. D.C. 1968) *បានដកស្រង់សំដីនៅក្នុង* Scabas ត្រង់ ៩៦២។ តុលាការក្នុងស្រុកបានសង្កេតឃើញថា ការធ្វើទុក្ខបុកម្នេញជនជាតិជ្វីហ្វបានក្លាយជាគោលនយោបាយផ្លូវការ ដោយដកស្រង់ Alstötter ដែលបានលើកឡើងថា "ការចូលរួមរបស់រដ្ឋាភិបាលគឺជាធាតុផ្សំសម្ភារៈនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" *ដោយដកស្រង់នៅក្នុង* Darcy & Powderly ត្រង់ ៩២។ **៤-៦.** *Mugesera និងជនផ្សេងទៀត ទល់នឹង រដ្ឋមន្ត្រីនៃពលរដ្ឋ និងអន្តោប្រវេសន៍* រឿងក្តី *Moreno ទល់នឹង ប្រទេសកាណាដា និង* រឿងក្តី *Sivakumar ទល់នឹង ប្រទេសកាណាដា* គឺជារឿងក្តីរដ្ឋបាលពាក់ព័ន្ធនឹងអនុសញ្ញាជនភៀសខ្លួនឆ្នាំ ១៩៥១។ *Sivakumar* គឺជារឿងក្តីតែមួយគត់ដែលលើកឡើងដោយផ្ទាល់ទៅនឹងលក្ខខណ្ឌនៃគោលនយោបាយរដ្ឋ។ ទោះបីជាវាទំនងជារកឃើញថាគ្មានលក្ខខណ្ឌនៃគោលនយោបាយរដ្ឋចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក៏ដោយ តុលាការពុំបានបែងចែករវាងថាតើមាន ឬ គ្មានលក្ខខណ្ឌនៃគោលនយោបាយ ឬ ថាតើបុគ្គលដែលពុំជាប់ទាក់ទងទៅនឹងរដ្ឋអាច ឬ ពុំអាចប្រព្រឹត្តឧក្រិដ្ឋប្រឆាំងមនុស្សជាតិបានឬយ៉ាងណាឡើយ។ *សូមមើល* Darcy & Powderly ត្រង់ ៩២-៩៣។ **៧.** *Trajković* ជាប់ពាក់ព័ន្ធនឹងការកាត់ទោសចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិពីព្រោះអំពើទាំងនេះត្រូវបានប្រព្រឹត្តឡើង "នៅក្នុងផែនការរួមគ្នាក្នុងគោលបំណងប្រព្រឹត្តអំពោះឃោរឃៅជាប្រព័ន្ធ [sic]"។ *ពាក់ព័ន្ធនឹង Trajković* តុលាការក្នុងស្រុកនៃ Giljan, P Nr 68/2000 ចុះថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០០១។ ពាក្យពេចន៍នេះបង្កប់នូវលក្ខខណ្ឌនៃផែនការរដ្ឋ។ **៨.** បាយការណ៍ឆ្នាំ ១៩៩៣ នៃអគ្គលេខាធិការ អ.ស.ប ពុំបានចែងដោយផ្ទាល់ថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សពុំកំណត់លក្ខខណ្ឌនៃគោលនយោបាយរបស់រដ្ឋ ឬតាមផែនការចាត់តាំងឡើយ។ *សូមមើល* របាយការណ៍នៃអគ្គលេខាធិការយោងតាមកថាខណ្ឌ ២ នៃក្រុមប្រឹក្សាសន្តិសុខ ៨០៨ (១៩៩៣) S/25703 ចុះថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ១៩៩៣ កថាខណ្ឌ ៤៧-៤៨។ **៩.** របាយការណ៍គណៈកម្មការនីតិកម្មអន្តរជាតិ ("គ.ន.អ") នៅក្នុងសម័យប្រជុំលើកទី ៤៣ ពុំបានដកចេញជាក់លាក់នៃគោលនយោបាយអង្គការ ឬ រដ្ឋ ពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ លក្ខខណ្ឌត្រូវបានដាក់បញ្ចូលនៅក្នុងនិយមន័យក្រោយសម័យប្រជុំ គ.ន.អ លើកទី ៤៨ (*សូមមើលខាងលើ* កំណត់សម្គាល់លេខ ៣១)។ របាយការណ៍គណកម្មការនីតិកម្មអន្តរជាតិស្តីពីការងារនៅក្នុងសម័យប្រជុំលើកទី ៤៣ ថ្ងៃទី ២៩ ខែ មេសា - ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩១ កំណត់ហេតុផ្លូវការនៃមហាសន្និបាត សម័យប្រជុំលើកទី ៤៦ ឯកសារបន្ថែមលេខ ១០ ឯកសារ អ.ស.ប លេខ A/46/10 ទំព័រ ១០៣-១០៤។ **១០.** របាយការណ៍ គ.ន.អ ក្នុងសម័យប្រជុំលើកទី ៤៧ បញ្ជាក់អំពីការពុំមានការឯកភាពជាឯកច្ឆ័ន្ទស្តីពីលក្ខខណ្ឌនៃគោលនយោបាយរដ្ឋ។ របាយការណ៍គណៈកម្មការនីតិកម្មអន្តរជាតិស្តីពីការងារនៅក្នុងសម័យប្រជុំលើកទី ៤៧ ថ្ងៃទី ២ ខែ ឧសភា - ថ្ងៃទី ២១ កក្កដា ឆ្នាំ ១៩៩៥ កំណត់ហេតុផ្លូវការនៃមហាសន្និបាត សម័យប្រជុំលើកទី ៥០ ឯកសារបន្ថែមលេខ ១០ ឯកសារ អ.ស.ប លេខ A/50/10 ទំព័រ ២៥ កថាខណ្ឌ ៨៩។

ដែលត្រូវបានដកស្រង់*គាំទ្រ*យ៉ាងជាក់លាក់លើលក្ខខណ្ឌនៃគោលនយោបាយ[31] ហើយប្រភពចំនួន ១ ដែលត្រូវបានដកស្រង់ ពុំបានលើកឡើងអំពីលក្ខខណ្ឌនៃគោលនយោបាយទាំងស្រុងនោះទេ[32]។ អង្គជំនុំជម្រះ

[31] **១.** មាត្រា ៦(គ) នៅក្នុងធម្មនុញ្ញនៃតុលាការយោធា IMT បានផ្តល់យុត្តាធិការឲ្យតុលាការយោធា IMT ដើម្បីចោទប្រកាន់បុគ្គលដែលបានធ្វើសកម្មភាពដើម្បីប្រយោជន៍ប្រទេសសម្ព័ន្ធមិត្តអឺរ៉ុប។ *សូមមើល ខាងលើ* កថាខណ្ឌ ៨។ **២.** សាលក្រមតុលាការយោធា IMT បានដាក់បញ្ចូលលក្ខខណ្ឌនៃគោលនយោបាយជាផ្នែកមួយនៃការកាត់ទោសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ *សូមមើលខាងលើ* កថាខណ្ឌ ៨ កំណត់សម្គាល់លេខ ២២។ *សូមមើល* រឿងក្តី *សហរដ្ឋអាមេរិក ទល់នឹង* von Weizsaecker (រឿងក្តីក្រសួង) ការជំនុំជម្រះនៅចំពោះមុខតុលាការយោធា Nuremberg អនុលោមតាមច្បាប់លេខ ១០ នៃក្រុមប្រឹក្សាត្រួតពិនិត្យ Vol. XIV ទំព័រ ៦១១ (១៩៤៩) (ការគូសបញ្ជាក់ខាងក្នុងត្រូវបានលុបចោល ការគូសបញ្ជាក់បន្ថែម)៖ "*អ្វីដែលបានធ្វើឡើងគឺស្របតាមគោលនយោបាយរដ្ឋាភិបាល* និងចោរកម្មគឺជាផ្នែកនៃកម្មវិធីសម្លាប់រង្គាល និងមិនមែនជាគោលដៅមួយក្នុងចំណោមគោលដៅផ្សេងទៀតឡើយ...ដោយគ្មានការសង្ស័យ អំពីទាំងអស់បែបនេះគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងជនណាដែលបានចូលរួម ឬ ដើរតួនាទីនៅក្នុងយល់ស្របនៅក្នុងការចូលរួមនេះគឺមានពិរុទ្ធភាពពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"។ **៣.** ពាក់ព័ន្ធនឹង *Ahlbrecht* តុលាការកំពូលនៃប្រទេសហូឡង់ដ៏បានសម្រេចថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានកំណត់លក្ខណៈដោយ "ភាពធ្ងន់ធ្ងរ និងភាពសាហាវឃោរឃៅរបស់វា ឬ ដោយវិសាលភាពរបស់វា ឬ ដោយករណីដែលថា ឧក្រិដ្ឋកម្មទាំងនេះបានបង្កើតជាផ្នែកមួយនៃប្រព័ន្ធដោយផ្អែកលើភាពភ័យខ្លាច ឬ បានបង្កើតចំណងទាក់ទងនៅក្នុងគោលនយោបាយចេតនាធ្វើឡើងប្រឆាំងនឹងក្រុមប្រជាជនជាក់លាក់" *ដោយដកស្រង់នៅក្នុង* Darcy & Powderly ត្រង់ ៩១។ **៤.** សៀវភៅប្រចាំឆ្នាំ ១៩៥៤ នៃ គ.ន.អ បានដាក់បញ្ចូលយ៉ាងជាក់លាក់នូវលក្ខខណ្ឌនៃគោលនយោបាយរបស់រដ្ឋ ឬតាមផែនការចាត់តាំង នៅក្នុងសេចក្តីព្រាងស្តីពីបទល្មើសឆ្នាំ ១៩៥៤ ដែលបានកំណត់និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិថាជា "អំពើអមនុស្សធម៌...ត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងប្រជាជនស៊ីវិលដោយសារហេតុផលវប្បធម៌ សាសនា ពូជសាសន៍ នយោបាយ ឬ សង្គម ដោយអាជ្ញាធររដ្ឋ ឬ ដោយបុគ្គលឯកជនដែលបានធ្វើសកម្មភាពញុះញង់ ឬ ដោយមានការអត់ឱនពីអាជ្ញាធរទាំងនេះ"។ *សូមមើល* សៀវភៅប្រចាំឆ្នាំនៃគណកម្មការនីតិកម្មអន្តរជាតិ ឆ្នាំ ១៩៥៤ Vol. 11 ទំព័រ ១៥០ មាត្រា ២(១១)។ *សូមមើលផងដែរ* Kai Ambos & Steffen Wirth, *The Current Law of Crimes Against Humanity: An Analysis of UNTAET Regulation 15/2000* 13 Crim. L.F., 26 (2002) ("Ambos & Wirth")។ Schabas ត្រង់ ៩៦៤។ **៥.** របាយការណ៍ គ.ន.អ ក្នុងសម័យប្រជុំលើកទី ៤៨ បានរួមបញ្ចូលនៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនូវលក្ខខណ្ឌមួយដែលលើកឡើងថា អំពើទាំងឡាយ "ត្រូវបានញុះញង់ ឬ បង្គាប់បញ្ជាដោយរដ្ឋាភិបាល ឬ ដោយអង្គការ ឬ ក្រុមណាមួយ" ដើម្បីគោលបំណងនៃ "ការដកចេញស្ថានភាពដែលបុគ្គលម្នាក់បានប្រព្រឹត្តអំពើអមនុស្សធម៌មួយ ក្នុងខណៈដែលធ្វើសកម្មភាពទៅតាមគំនិតផ្តួចផ្តើមរបស់ខ្លួន...នៅពេលដែលគ្មានការជម្រុញ ឬ ការណែនាំពីរដ្ឋាភិបាល ឬ ក្រុម ឬ អង្គការ។ របាយការណ៍របស់គណៈកម្មានីតិកម្មអន្តរជាតិស្តីពីការងារនៅក្នុងសម័យប្រជុំលើកទី ៤៨ ថ្ងៃទី ៦ ខែ ឧសភា - ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ កំណត់ហេតុផ្លូវការនៃមហាសន្និបាត សម័យប្រជុំលើកទី ៥១ ឯកសារបន្ថែមលេខ ១០ ឯកសារ អ.ស.ប លេខ A/51/10 ទំព័រ ៤៧ កថាខណ្ឌ ៥។

[32] របាយការណ៍ គ.ន.អ នៅក្នុងសម័យប្រជុំលើកទី ៤៦ ពុំបានលើកឡើងអំពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។ ដូចបានកត់សម្គាល់ដោយអ្នករាយការណ៍ពិសេសនៅក្នុងរបាយការណ៍ "ផ្នែកទីពីរនៃសេចក្តីព្រាងក្រម ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដោយខ្លួនឯង

សាលាឧទ្ធរណ៍ក៏ពុំបានយកចិត្តទុកដាក់លើកឡើងប្រភពពាក់ព័ន្ធនានា ដែលគាំទ្រការដាក់បញ្ចូលលក្ខខណ្ឌនៃគោលនយោបាយនោះទេ[33]។ សាលដីកាលើរឿងក្តី *Kunarac* ត្រូវ បានសម្រេច *ក្រោយ* យុត្តាធិការតាមពេលវេលារបស់ អ.វ.ត.ក ហើយដូចបានបង្ហាញខាងលើ សាលដីកាលើរឿងក្តី *Kunarac* មិនអាចយកមកធ្វើជាមូលដ្ឋានជាភ័ស្តុតាងថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិពុំទាមទារលក្ខខណ្ឌនៃគោលនយោបាយ តាមផែនការចាត់តាំង ឬរបស់រដ្ឋឡើយ។

### ៧. លក្ខខណ្ឌកំណត់ថា ការវាយប្រហារមានចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធ អនុលោមតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងឆ្នាំ ១៩៧៥-១៩៧៩

11. ទោះបីជាពុំមានចែងច្បាស់លាស់នៅក្នុងមាត្រា ៥ ក៏ដោយ នៅក្នុងឆ្នាំ ១៩៧៥-៧៩ ច្បាប់ទំនៀមទម្លាប់អន្តរជាតិបានកំណត់ថា ការវាយប្រហារមានចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធ[34]។ អង្គជំនុំ

---

នឹងត្រូវបានលើកឡើងនៅក្នុងរបាយការណ៍បន្ទាប់នៅក្នុងសម័យប្រជុំគណៈកម្មការលើកទី ៤៧"។ របាយការណ៍នៃគណៈកម្មការនីតិកម្មអន្តរជាតិស្តីពីការងារនៅក្នុងសម័យប្រជុំលើកទី ៤៦ ថ្ងៃទី ២ ខែ ឧសភា - ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៩៤ កំណត់ហេតុផ្លូវការនៃមហាសន្និបាត សម័យប្រជុំលើកទី ៤៩ ឯកសារបន្ថែមលេខ ១០ ឯកសារ អ.ស.ប លេខ A/49/10 ទំព័រ ៧៥ កថាខណ្ឌ ៩៤។

[33] មាត្រា ៧(២)(ក)នៅក្នុងលក្ខន្តិកៈនៃតុលាការ ICC ចែងយ៉ាងច្បាស់លាស់ថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានប្រព្រឹត្តឡើង "អនុលោមតាម ឬ ដើម្បីសម្រេចគោលនយោបាយអង្គការ ឬ រដ្ឋ ដើម្បីប្រព្រឹត្តការវាយប្រហារ"។ *សូមមើលស្ថានភាពនៅក្នុងសាធារណរដ្ឋកែនយ៉ា* ស្ថានភាពនៅក្នុងសាធារណរដ្ឋកែនយ៉ា ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១០ កថាខណ្ឌ ៨៣-៩៣។ Schabas ត្រង់ ៩៦២-៦៣។ Ambos & Wirth ត្រង់ ២៦។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ខកខានមិនបានលើកឡើងរឿងក្តី *Regina ទល់នឹង Finta* ដែលជារឿងក្តីល្បីមួយនៅក្នុងប្រទេសកាណាដាស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលភាគច្រើនតុលាការកំពូលបានសម្រេចថា "សកម្មភាព ឬ គោលនយោបាយរដ្ឋ" គឺជាលក្ខខណ្ឌនីត្យានុកូលចាំបាច់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" *ដោយដកស្រង់ចេញពីក្នុង* Schabas ត្រង់ ៩៦៣។ *សូមមើល* Darcy & Powderly ត្រង់ ៩៣។ Cryer ត្រង់ ២៣៨ កំណត់សម្គាល់លេខ ៤៣។

[34] *សូមមើល* ញត្តិមួយផ្សេងទៀតស្តីពីការកំហិតលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ កថាខណ្ឌ ៨-៩។ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៨៨-១៨៩។ ការឆ្លើយតបទៅនឹងចម្លើយតបរបស់ ក.ស.ព ចំពោះបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៨៦-៩៣។ ចម្លើយតបរបស់ ក.ស.ព ទៅនឹងសំណើសុំដកចេញលក្ខខណ្ឌនៃចំណងទាក់ទង កថាខណ្ឌ ២០-៣៤។ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីចំណងទាក់ទង កថាខណ្ឌ ២៦-៦១។ យ៉ាងហោចណាស់ ឋានៈនៃលក្ខខណ្ឌចំណងទាក់ទងមានលក្ខណៈស្រពិចស្រពិល ដែលមានន័យថា វាអនុវត្តនៅ អ.វ.ត.ក។ *សូមមើល* ចំពោះសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣០៧-៣១១ ដែលអង្គបុរេជំនុំជម្រះបានវិភាគឋានៈនៃលក្ខខណ្ឌចំណងទាក់ទងអនុលោមតាមច្បាប់ទំនៀមទម្លាប់ចាប់ពីឆ្នាំ ១៩៧៥-៧៩ សេចក្តី-សម្រេចនេះបានអនុវត្តគោលការណ៍*គ្មានការកាត់ទោសពីរដង* ដោយសារតែលក្ខណៈស្រពិចស្រពិលនៃឋានៈលក្ខខណ្ឌចំណងទាក់ទង

ជម្រះសាលាដំបូងមានកំហុសនៅពេលសម្រេចថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិចាប់ពីឆ្នាំ ១៩៧៥-៧៩ បានដកចេញចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធ ចេញពីក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[35]។

12. មាត្រា ៦(គ) នៅក្នុងធម្មនុញ្ញនៃតុលាការយោធា IMT[36] ចែងថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមិនអាចមានអត្ថិភាពឡើយ លើកលែងតែវាកើតឡើងស្របជាមួយនឹងឧក្រិដ្ឋកម្មសង្គ្រាម ឬ ឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព[37]។ សាលក្រមនៃតុលាការយោធា IMT[38] និងគោលការណ៍ Nuremberg ឆ្នាំ ១៩៥០ ឆ្លុះបញ្ចាំង

---

ហើយបានសន្និដ្ឋាន "និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងធម្មនុញ្ញ Nuremberg និងគោលការណ៍ Nuremberg បានបន្តអនុវត្តនៅក្នុងចន្លោះឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ថា ចំណងទាក់ទងជាមួយនឹងឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព ឬ ឧក្រិដ្ឋកម្មសង្គ្រាមនៅតែជាធាតុផ្សំចាំបាច់" (កថាខណ្ឌ ៣១១)។ *សូមមើលផងដែរ* បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីចំណងទាក់ទង កថាខណ្ឌ ៦០-៦១។

[35] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំដកចេញលក្ខខណ្ឌនៃចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធចេញពីក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១១ ឯកសារលេខ E95/8។ អង្គជំនុំជម្រះតុលាការកំពូលពុំទាន់បានសម្រេចលើបញ្ហានេះនៅឡើយ។ ខណៈរកឃើញថាបណ្តឹងសាទុក្ខចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពុំអាចទទួលយកបាន អង្គជំនុំជម្រះតុលាការកំពូលពុំបានសម្រេចលើអង្គសេចក្តីនៃបណ្តឹងសាទុក្ខនេះនៅឡើយទេ។ សេចក្តី-សម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំដកចេញលក្ខខណ្ឌនៃចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធ ចេញពីក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២ ឯកសារលេខ E95/8/4/1។

[36] ដូចបានធ្វើវិសោធនកម្មតាមរយៈពិធីសារចុះថ្ងៃទី ៦ ខែ តុលា។ កិច្ចដំណើរការនីតិវិធីជំនុំជម្រះ Nuremberg Volume I: ពិធីសារផ្តល់សច្ចាប័នលើភាពចន្លោះប្រហោងនៅក្នុងធម្មនុញ្ញ (ថ្ងៃទី ៦ ខែ តុលា ឆ្នាំ ១៩៤៥) *អាចមើលបានតាមរយៈ* http://avalon.law.yale.edu/imt/imtprot.asp។

[37] *សូមមើល* Stuart Ford, *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា: តើមានតម្រូវឱ្យមានចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធដែរឬទេ?* 24 UCLA Pac. Basin L.J. 125 កំណត់សម្គាល់លេខ ៧០ (ឆ្នាំ ២០០៦-២០០៧) ("Ford") *ដោយដកស្រង់* Leslie C. Green, *International Regulations of Armed Conflicts, in* 1 International Criminal Law, Crimes 355, 369 (M. Cherif Bassiouni ed., 2ed. 1999)។

[38] សាលក្រមតុលាការយោធា IMT ត្រង់ ២៥៤។ ទោះបីជាលក្ខខណ្ឌនៃជម្លោះប្រដាប់អាវុធត្រូវបានដកចេញពីមាត្រា II នៅក្នុងច្បាប់លេខ ១០ នៃក្រុមប្រឹក្សាត្រួតពិនិត្យក៏ដោយក្តី **ក.** ចំណងទាក់ទងជាមួយនឹងយុត្តាធិការទៅនឹងធម្មនុញ្ញនៃតុលាការយោធា IMT នៅក្នុងច្បាប់លេខ ១០ នៃក្រុមប្រឹក្សាត្រួតពិនិត្យត្រង់មាត្រា I ធ្វើឱ្យអានុភាពនៃការលុបចោលនេះមានលក្ខណៈស្រពិចស្រពិល ដោយចៅក្រមបានទាមទារម្តងហើយម្តងទៀតនូវលក្ខខណ្ឌនៃចំណងទាក់ទងរវាងសង្គ្រាម និងសកម្មភាពរបស់ជនជាប់ចោទ និង **ខ.**

ការយល់ឃើញនេះ[39]។ ការពិភាក្សានៅក្នុងគណៈកម្មការនីតិកម្មអន្តរជាតិនៅចុងទសវត្សរ៍ឆ្នាំ ១៩៤០ និងដើមទសវត្សរ៍ឆ្នាំ ១៩៥០ ពាក់ព័ន្ធនឹងការវិវឌ្ឍជាវិជ្ជមាននៃច្បាប់អន្តរជាតិបានបង្ហាញថា ចំណងទាក់ទងរវាងអំពើជាក់លាក់ និងជម្លោះប្រដាប់អាវុធអន្តរជាតិត្រូវបានមើលឃើញថា ជាលក្ខខណ្ឌនីត្យានុកូលនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងអំឡុងពេលនោះ[40]។ ចាប់ពីទសវត្សរ៍ឆ្នាំ ១៩៥០ ដល់ ឆ្នាំ ១៩៧៩ មានភស្តុតាងតិចតួចអំពីការអនុវត្តរបស់រដ្ឋ និង*សច្ចធាណ៍ធម្មានុរូប* (opinion juris) ដែលបង្ហាញថា ចំណង

---

តុលាការសម្ព័ន្ធមិត្តអាល្លឺម៉ង់ដែលបានអនុវត្តច្បាប់នេះគឺជា "តុលាការក្នុងស្រុកដែលបានលើកឡើងច្បាប់ក្នុងស្រុកជាចំបង"។ Schwelb ត្រង់ ២១៨-១៩។

[39] គោលការណ៍នៃច្បាប់អន្តរជាតិដែលត្រូវបានទទួលស្គាល់នៅក្នុងធម្មនុញ្ញរបស់តុលាការ Nuremberg និងនៅក្នុងសាលក្រមរបស់តុលាការនេះ ឯកសារ អ.ស.ប លេខ A/1316 (1950) គោលការណ៍ VI (គ)។ *សូមមើលផងដែរ* ការតម្កល់គោលការណ៍នៃច្បាប់អន្តរជាតិដែលត្រូវបានតទួលស្គាល់ដោយតុលាការ Nuremberg *ត្រូវបានអនុម័ត*នៅថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៤៦ សេចក្តីសម្រេចនៃមហាសន្និបាតលេខ ៩៥(១), U.N. G.A.O.R 1st Sess., កិច្ចប្រជុំពេញអង្គលើកទី ៥៥ ឯកសារ អ.ស.ប លេខ A/64/Add.1 (1946) ត្រង់ ១៨៨ ដែលបញ្ជាក់ថា លក្ខខណ្ឌនៃចំណងទាក់ទងនៅក្នុងធម្មនុញ្ញរបស់តុលាការយោធា IMT ពុំត្រូវបានមើលឃើញថាជាលក្ខខណ្ឌយុត្តាធិការជាក់លាក់មួយប៉ុណ្ណោះទេ។

[40] *សូមមើល*សេចក្តីព្រាងក្រមស្តីពីបទល្មើសប្រឆាំងនឹងសន្តិភាព និងសន្តិសុខមនុស្សជាតិ របាយការណ៍ដោយ J. Spiropoulos អ្នករាយការណ៍ពិសេស ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៥០ ("របាយការណ៍របស់ Spiropoulos") *អាចមើលបាន*នៅក្នុង 2 Y.B. Int'l Comm'n 253, 255 កថាខណ្ឌ ២ (ឆ្នាំ ១៩៥០) ដោយកត់សម្គាល់ថា អ្នករាយការណ៍ពិសេសពុំបានចងក្រងច្បាប់អន្តរជាតិដែលមានស្រាប់ប៉ុន្តែគ្រាន់តែបានចូលរួមនៅក្នុងការងារដែលមាន "លក្ខណៈមួយប៉ាន់ស្មាន" ប៉ុណ្ណោះ។ *សូមមើលផងដែរ ដូចខាងលើ* ២៥៧ កថាខណ្ឌ ២០ ដោយកត់សម្គាល់ថា គ.ន.អ បានពិភាក្សាបញ្ហា និងបានសន្និដ្ឋានថា សេចក្តីព្រាងក្រមស្តីពីបទល្មើសបង្ហាញអំពី "ការវិវឌ្ឍរីកចម្រើននៃច្បាប់អន្តរជាតិ"។ អវត្តមាននៃលក្ខខណ្ឌចំណងទាក់ទងនៅក្នុងអនុសញ្ញាស្តីពីប្រល័យពូជសាសន៍ពុំមានលក្ខណៈជាក់លាក់នោះទេ។ *សូមមើល* Guénaël Metraux, *Crimes Against Humanity in the Jurisprudence of the International Criminal Tribunal for the Former Yugoslavia and for Rwanda*, 43 Harv. Int'l L.J. 237, 302-06 (ឆ្នាំ ២០០២)។ របាយការណ៍របស់ Spiropoulos បានសង្កេតឃើញថា អវត្តមាននៃលក្ខខណ្ឌចំណងទាក់ទងពីអនុសញ្ញាស្តីពីបទប្រល័យពូជសាសន៍ត្រូវបានមើលឃើញថាជាការបែកចែកឧក្រិដ្ឋកម្មនេះពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ *សូមមើល* សេចក្តីព្រាងក្រមស្តីពីបទល្មើស ត្រង់ ២៦៣ កថាខណ្ឌ ៦៥។ *សូមមើលផងដែរ* Ford ត្រង់ ១៥២-១៥។ Diane F. Orentlicher, *Settling Accounts: The Duty to Prosecute Human Rights Violations of a Prior Regime,* 100 Yale L.J. 2537 កំណត់សម្គាល់លេខ ២១៦ (ឆ្នាំ ១៩៩១)៖ "និយមន័យនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍...នៅក្នុងអនុសញ្ញាស្តីពីបទប្រល័យពូជសាសន៍ ពុំកើតឡើងដំណាលគ្នាជាមួយនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានដាក់ទោសនៅ Nuremberg នោះទេ"។ *សូមមើល* សេចក្តីសង្ខេបនៃកិច្ចប្រជុំលើកទី ៤៨ នៃគណៈកម្មការនីតិកម្មអន្តរជាតិ ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ១៩៥០ *អាចមើលបានតាមរយៈ* http://untreaty.un.org/ilc/documentsation/english/a_cn4_34.pdf។

ទាក់ទងពុំមែនជាធាតុផ្សំចាំបាច់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទៀតទេ[41]។ ការជំទាស់ចំពោះការលុបចោលចំណងទាក់ទងបានបន្តលើកឡើង រហូតមកទល់ពេលចរចាលក្ខន្តិកៈ របស់តុលាការ ICC ឆ្នាំ ១៩៩៨[42]។

---

[41] អនុសញ្ញាអន្តរជាតិដែលត្រូវបានព្រាងឡើង ឬ អនុម័តចេញពីឆ្នាំ ១៩៦៨-១៩៧៩ ពុំមែនជាសញ្ញាបញ្ជាក់អំពីការអនុវត្តរបស់រដ្ឋ និង *ទស្សនៈច្បាប់* ពីឆ្នាំ ១៩៧៥-៧៩ នោះទេ។ *សូមមើល* ត្រង់ ១៥៩-៦៧ ដោយកត់សម្គាល់ថា អនុសញ្ញាឆ្នាំ ១៩៦៨ ស្តីពីការអនុវត្តមិនបាននៃអាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ៖ **ក.** គឺជាឯកសារនយោបាយដែលទទួលបានការគាំទ្រពីរដ្ឋសមាជិកនៃ អ.ស.ប មិនដល់ពាក់កណ្តាលឡើយ (Ford ត្រង់ ១៦១-៦២)។ **ខ.** ផ្តល់ជា "ចំណាប់អារម្មណ៍រួម" ដែលថា ចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធគឺជាលក្ខខណ្ឌមួយលើកលែងតែនៅក្នុងករណីឧក្រិដ្ឋកម្មជាក់លាក់ ដូចអំពើអាប៉ាថេត និងអំពើប្រល័យពូជសាសន៍ បានវិវឌ្ឍ និងដោយពុំមានការជាប់ទាក់ទងដោយផ្ទាល់ទៅនឹងជម្លោះប្រដាប់អាវុធ (Ford ត្រង់ ១៦០)។ និង **គ.** បង្ហាញថា គ្មានការអនុវត្តទូទៅនៅក្នុងចំណោមរដ្ឋមានអត្ថិភាពនៅពេលនេះឡើយ (Ford ត្រង់ ១៦៧, ១៨៣)។ *សូមមើលផងដែរ* Robert H. Miller, *The Convention on the Non-Applicability of Statutory Limitations to War Crimes and Crimes Against Humanity,* 65 Am. J. Int'l L. 477 ៥០០ (ឆ្នាំ ១៩៧១) ដោយកត់សម្គាល់ថា រដ្ឋបានបោះឆ្នោតប្រឆាំងនឹងអនុសញ្ញាឆ្នាំ ១៩៦៨ ដោយហេតុថា រដ្ឋទាំងនេះ "ចាត់ទុកថាវិការៈនៃអនុសញ្ញានេះឃើញមានច្រើន និងមានលក្ខណៈជាសារវ័ន្តនៅក្នុងលក្ខណៈដែលថា រដ្ឋពុំអាចគាំទ្រអនុសញ្ញានេះឡើយ" ជាពិសេស ពីព្រោះអនុសញ្ញានេះបានរំលោភគោលការណ៍នៃអានុភាពមិនមានប្រតិសកម្ម។ អនុសញ្ញាអឺរ៉ុបឆ្នាំ ១៩៧៤ ស្តីពីភាពមិនអាចអនុវត្តបាននៃអាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម និងអនុសញ្ញាអន្តរជាតិស្តីបីការបង្ក្រាប និងការដាក់ទណ្ឌកម្មឧក្រិដ្ឋកម្មអាប៉ាថេត (ដែលចូលជាធរមាននៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៧៦) ពុំបានគាំទ្រជាក់លាក់លើការលើកឡើងថា ចំណងទាក់ទងពុំមែនជាលក្ខខណ្ឌទៀតឡើយមកត្រឹមឆ្នាំ ១៩៧៥-៧៩។ *សូមមើល* Ford ត្រង់ ១៦៧-១៦៩។ Yoram Dinstein *International Criminal Law* 20 Isr. L. Rev. 2006, 217 (ឆ្នាំ ១៩៨៥) ដែលកត់សម្គាល់ថា អនុសញ្ញាស្តីពីអាប៉ាថេតក្នុងឆ្នាំ ១៩៧៣ គឺជាឯកសារនយោបាយដែលមានគោលបំណង "អនុវត្តការបែងចែកពូជសាសន៍ និងការរើសអើងនៅក្នុងអាហ្វ្រិកខាងត្បូង"។ *សូមមើល* United Nations, *Multilateral Treaties Deposited with the Secretary-General Treaty Series Database* "Status of Treaties" ជំពូកទី IV ៧ បានបញ្ជាក់ថា មកត្រឹមថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ មានរដ្ឋសមាជិកនៃ អ.ស.ប ចំនួនតែ ៤៨ ប៉ុណ្ណោះ ក្នុងចំណោមរដ្ឋសមាជិកទាំង ១៤៨ បានចុះហត្ថលេខា ផ្តល់សច្ចាប័ន ឬ ចូលជាសមាជិកអនុសញ្ញាស្តីពីអាប៉ាថេត ឆ្នាំ ១៩៧៣នេះ។ និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិរួមមាននៅក្នុងសាលក្រមរបស់តុលាការយោធា IMT គឺជាឯកសារមូលដ្ឋាន។

[42] *សូមមើល* Bassiouni, Crimes Against Humanity in International Criminal Law ត្រង់ ១៩៩ *ដោយដកស្រង់* របាយការណ៍ចុងក្រោយនៃគណៈកម្មាធិការរៀបចំ ចុះថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ១៩៩៨ ឯកសារ អ.ស.ប លេខ A/CONF. 183/Add.1 ផ្នែកទី I មាត្រា ៥ ទំព័រ ២៦។ សេចក្តីសង្ខេបកំណត់ហេតុនៃកិច្ចប្រជុំលើកទី ៣ សន្និសីទការទូត អ.ស.ប របស់អគ្គរដ្ឋទូតពេញសមត្ថភាព ស្តីពីការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ A/CONF.183.1/SR.3 ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨។ អ្នកធ្វើសេចក្តីព្រាងច្បាប់លក្ខន្តិកៈរបស់តុលាការ ICTY ពិចារណាឃើញថា វា "ច្បាស់លាស់ណាស់" ថា និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិអនុលោមតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ រួមបញ្ចូលទាំងចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធ។ *សូមមើល* William A. Schabas, The International Criminal Court: A Commentary on the Rome Statute

### ៨. ការដឹងឮ

13. ធាតុផ្សំ*អត្តនោម័ត* អាចទាញចេញពីមាត្រា ៥ ពោលគឺ ជនជាប់ចោទត្រូវដឹងថា **ក.** មានការវាយប្រហារលើប្រជាជនស៊ីវិល *និង* **ខ.** អំពើរបស់ជនជាប់ចោទជាផ្នែកមួយនៃការវាយប្រហារនោះ[43]។

### ខ. បទល្មើសជាដើមចម

14. ដើម្បីកំណត់បទល្មើសនានាដែលបានចោទប្រកាន់ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ បទល្មើសនីមួយៗត្រូវបង្ហាញឲ្យឃើញនូវចំណុច ដូចជា **ក.** ធាតុផ្សំយុត្តាធិការ/*លក្ខខណ្ឌតម្រូវទូទៅ* នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (*សូមមើលខាងលើ*) និង **ខ.** ធាតុផ្សំបទល្មើស (*សូមមើលខាងក្រោម*)[44]។

### ១. ការធ្វើមនុស្សឃាត

15. ការធ្វើមនុស្សឃាតគឺ ៖ **ក.**ជាការធ្វើឲ្យមនុស្សស្លាប់ **ខ.**ជាលទ្ធផលនៃអំពើសកម្ម ឬអកម្មខុសច្បាប់របស់ចារី **គ.**ការរួមចំណែកយ៉ាងសំខាន់ដល់ការស្លាប់របស់ជនរងគ្រោះ និង **ឃ.**ត្រូវបានប្រព្រឹត្តដោយមានចេតនាសម្លាប់ ឬបង្កឲ្យមានរបួសកម្មធ្ងន់ធ្ងរលើរាងកាយ ដោយដឹងច្បាស់ថា អំពើសកម្ម ឬអកម្មរបស់ចារីទំនងជាធ្វើឲ្យមានការស្លាប់មនុស្ស[45]។

### ២. ការសម្លាប់រង្គាល

16. ការសម្លាប់រង្គាលគឺ ៖ **ក.**អំពើសកម្ម ឬអកម្ម ឬការផ្សំគ្នានៃអំពើទាំងពីរនេះ **ខ.**សកម្មភាពនាំដល់ការស្លាប់មនុស្សជាទ្រង់ទ្រាយធំ និង **គ.**អំពើត្រូវបានធ្វើឡើងក្នុងចេតនាដោយធ្វើឲ្យមនុស្សស្លាប់ក្នុងទ្រង់ទ្រាយធំ ឬបង្កឲ្យមានរបួសកម្មធ្ងន់ធ្ងរលើរាងកាយ ឬបង្កឲ្យមានស្ថានភាពរស់នៅដែលធ្វើឲ្យមានការស្លាប់ដោយដឹងច្បាស់ថា អំពើសកម្ម ឬអកម្មទំនងជាបង្កឲ្យមានការស្លាប់មនុស្សជាចំនួនច្រើន[46]។ ក្រៅពីនេះ មេធាវី

---

145 (OUP 2010) (“Schabas”)។ ច្បាប់លក្ខន្តិកៈនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា (“តុលាការ ICTR”) កើតចេញពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ ហើយ ដោយពិចារណាលើសេចក្តីព្រាងប្រវត្តិរបស់តុលាការនេះ វាពុំមែនជាការប្រកាសនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងឆ្នាំ ១៩៩៤ នោះទេ។ *សូមមើល*របាយការណ៍នៃអគ្គលេខាធិការអនុលោមតាមកថាខណ្ឌ ៥ នៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ៩៥៥ (ឆ្នាំ ១៩៩៤) S/1995/134 ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ កថាខណ្ឌ ១២។ ក្រុមប្រឹក្សាសន្តិសុខ អ.ស.ប កិច្ចប្រជុំលើកទី ៣៤៥៣ S/PV.3453 ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ទំព័រ ៩។ Schabas ត្រង់ ១៤៥។

[43] សាលក្រមលើរឿងក្តី *ឌុច* កថាខណ្ឌ ៣១៩។

[44] *សូមមើលដូចខាងលើ* កថាខណ្ឌ ២៩៧។

[45] *ដូចខាងលើ*, កថាខណ្ឌ ៣៣១ ដល់ ៣៣។

[46] *ដូចខាងលើ*, កថាខណ្ឌ ៣៣៤ ដល់ ៣៨។

ការពារក្ដីធ្វើសារណាដូចតទៅ ៖ ដំបូង អនុវត្តគោលការណ៍សច្ចធារណ៍នៃនិរទោស (*in dubio pro reo*),[47] ដែលការសម្លាប់មនុស្សម្នាក់ ឬការសម្លាប់មនុស្សចំនួនកំណត់មួយ មិនអាចចាត់ទុកថាជាការសម្លាប់រង្គាលឡើយ។ ទោះបីជាអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ពុំចាំបាច់មានចំនួនអប្បបរមានៃជនរងគ្រោះក៏ដោយ[48] ក៏ធាតុផ្សំនេះនៅតែមានភាពមិនច្បាស់លាស់។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិតម្រូវបន្ថែមទៀតថា ចារីបានសម្លាប់មនុស្សម្នាក់ ឬច្រើននាក់ ឬជាផ្នែកមួយនៃការសម្លាប់ប្រជាជនស៊ីវិលក្នុងទ្រង់ទ្រាយធំ[49]។ ទោះជាយ៉ាងនេះក្ដី រឿងក្ដី *Vasiljević* បានបញ្ជាក់ថា ការសម្លាប់មនុស្សម្នាក់ ឬចំនួនជាក់លាក់ណាមួយ មិនមែនជាការសម្លាប់រង្គាលឡើយ[50]។ ទីពីរ ជនងរងគ្រោះប្រាកដជាត្រូវប្រឈមនឹងលក្ខខណ្ឌ *ដែលជៀសមិនរួចពី* សេចក្ដីស្លាប់នោះឡើយ[51]។

---

[47] រដ្ឋធម្មនុញ្ញ មាត្រា ៣៨។ *សូមមើលផងដែរ* សារណា កថាខណ្ឌ ៣។

[48] *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង* Stakić, ឯកសារ IT-97-24-A, សាលដីកា, ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ ("សាលដីកាលើករណីរបស់ *Stakič*"), កថាខណ្ឌ ២៦០, *ដកស្រង់ពី រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង* *Ntakirutimana & Ntakirutimana*, ឯកសារ ICTR-96-10-A & ICTR-96-17-A, សាលដីកា, ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៤ ("សាលដីកាលើករណីរបស់ *Ntakirutimana*"), កថាខណ្ឌ ៥១៦។

[49] ធាតុផ្សំនៃឧក្រិដ្ឋកម្មរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ, មាត្រា ៧(១)(គ), កថាខណ្ឌ ១ ដល់ ២។

[50] *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង* *Vasiljević*, ឯកសារ IT-98-32-T, សាលក្រម, ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០២, កថាខណ្ឌ ២២៧, ដែលបានរកឃើញថា ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះការសម្លាប់រង្គាលមានទំនាក់ទំនងតែចំពោះបុគ្គលទាំងឡាយណាដែលទទួលខុសត្រូវក្នុងការស្លាប់មនុស្សក្នុងចំនួនច្រើនប៉ុណ្ណោះ។ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្ដី *Vasiljević* បានកត់សម្គាល់ឃើញថា និយមន័យនៃការសម្លាប់រង្គាលរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិពុំមានបញ្ចូលលក្ខខណ្ឌនេះទេ ពីព្រោះខ្លួនយល់ថា លក្ខខណ្ឌដូចនេះអាចមានភាពស្មុគស្មាញហួសហេតុរហូតដល់មិនអាចធ្វើការវិនិច្ឆ័យក្ដីបាន ហើយជាលទ្ធផលក៏បានច្រានចោល (*ដូចខាងលើ*, លេខ ៥៨៦)។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់បន្ថែមទៀតថា ៖ "កង្វល់ដូចនេះនៅតែមាននៅឡើយសម្រាប់តុលាការ *នេះ* ពីព្រោះវាហួសពីវិសាលភាពនៃការពិចារណារបស់ខ្លួន ជាពិសេសនៅក្នុងករណីបច្ចុប្បន្ន នៅពេលដែលមានការអនុម័តនិយមន័យដែលលក្ខណៈទូលំទូលាយអាចជាការអន្តរាយដល់ជនជាប់ចោទ។ តុលាការអន្តរជាតិនេះត្រូវតែអនុវត្តច្បាប់ដែលខ្លួនបានរកឃើញ មិនមែនជាច្បាប់ដែលខ្លួនចង់ឲ្យមាននោះទេ។ ជាងនេះទៀត និយមន័យដែលត្រូវបានអនុម័តជាចុងក្រោយរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ នៅក្នុងធាតុផ្សំឧក្រិដ្ឋកម្មមានឥទ្ធិពលផ្ទាល់ពីនិយមន័យនៃ 'ការសម្លាប់រង្គាល' ដែលបានកំណត់នៅក្នុងសាលក្រមលើករណីរបស់ *Kayishema and Ruzindana*, ដែលចែងថា ការសម្លាប់មនុស្សក្នុងចំនួនកំណត់មួយ ឬសូម្បីតែការសម្លាប់តែម្នាក់គត់ អាចចាត់ទុកថាជាការសម្លាប់រង្គាល ប្រសិនបើការសម្លាប់នោះគឺជាផ្នែកមួយនៃព្រឹត្តិការណ៍សម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំ … អង្គជំនុំជម្រះសាលាដំបូងនៃករណីរបស់ *Kayishema and Ruzindana* មិនបានបង្ហាញពីការអនុវត្តរបស់រដ្ឋណាមួយដើម្បីគាំទ្រដល់ការសម្រេចរបស់ខ្លួនដូចនេះទេ ដែលជាលទ្ធផលធ្វើឲ្យមានភាពទន់ខ្សោយយ៉ាងខ្លាំងដល់តម្លៃនៃការសម្រេចដែលអាចប្រើជាករណីយុត្តិសាស្ត្រ។ អង្គជំនុំជម្រះសាលាដំបូងមិនបានរកឃើញថាមានការអនុវត្តរបស់រដ្ឋណាមួយដែលគាំទ្រដល់ការសម្រេចក្នុង

### ៣. ការធ្វើទុក្ខបុកម្នេញ (ដោយមូលហេតុនយោបាយ និងពូជសាសន៍)

17. ការធ្វើទុកបុកម្នេញ គឺជា ៖ **ក.**អំពើសកម្ម ឬអកម្ម **ខ.**អំពើរើសអើងជាក់ស្តែង **គ.**បដិសេធ ឬបំពារបំពានដល់សិទ្ធិជាមូលដ្ឋាន និង **ឃ.**ត្រូវបានប្រព្រឹត្តដោយចេតនាច្បាស់លាស់ក្នុងការរើសអើងដោយសារមូលហេតុនយោបាយ ជាតិសាសន៍ ឬសាសនា[52]។ តាមពិត ការរើសអើង *មិន*កើតមានឡើងឡើយ ប្រសិនបើមានកំហុសនៃអង្គហេតុពាក់ព័ន្ធនឹងសមាជិកភាពនៃជនរងគ្រោះនៅក្នុងក្រុមគោលដៅនោះ[53]។ មាត្រា ៥ ពុំមានបញ្ចូលពាក្យពេចន៍ដែលកំណត់ច្បាស់លាស់អំពីទង្វើនៃការធ្វើទុក្ខបុកម្នេញ ទៅក្នុងអំពើដែលមានទំនាក់ទំនងជាមួយនឹងឧក្រិដ្ឋកម្មដទៃទៀត ដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ទេ។ ទោះជាយ៉ាងនេះក្តី អនុលោមតាមមាត្រា ៩ នៃកិច្ចព្រមព្រៀង និយមន័យជាធរមាននៃការធ្វើទុក្ខបុកម្នេញត្រូវតែយកមកពិចារណាឲ្យស្របតាមនិយមន័យនៃការធ្វើទុក្ខបុកម្នេញរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ ចំពោះជនដែលមានទំនាក់ទំនងជាមួយនឹងឧក្រិដ្ឋកម្មផ្សេងៗទៀត នៅក្នុងយុត្តាធិការរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិនេះ[54]។

### ៤. ការផ្លាស់ប្តូរទីកន្លែងដោយបង្ខំ

18. អង្គជំនុំជម្រះសាលាដំបូងពុំមានយុត្តាធិការដើម្បីធ្វើសវនាការលើការផ្លាស់ប្តូរទីកន្លែងដោយបង្ខំទេ[55]។ អង្គហេតុនេះពុំបានចែងច្បាស់លាស់នៅក្នុងមាត្រា ៥ នោះទេ។ ដោយតុលាការកម្ពុជាផ្អែកលើប្រព័ន្ធច្បាប់ស៊ីវិលជាមូលដ្ឋាននោះ អ.វ.ត.ក មានយុត្តាធិការទៅលើតែឧក្រិដ្ឋទាំងឡាយណាដែលមានចែងយ៉ាងច្បាស់ប៉ុណ្ណោះ[56]។ ការផ្លាស់ប្តូរទីកន្លែងដោយបង្ខំក៏មិនត្រូវបានចែងយ៉ាងច្បាស់លាស់នៅក្នុង ៖ (ក)អង្គជំនុំជម្រះ

---

សាលក្រមលើករណីរបស់ *Kayishema and Ruzindana* ”។ *ដូចខាងលើ*, លេខ ៥៨៦។ *សូមមើលផងដែរ* សាលក្រម ឌុច, កថាខណ្ឌ ៣៣៦។

51 សាលដីកាលើករណីរបស់ *Stakić*, កថាខណ្ឌ ២៥៩; *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* *Gacumbitsi*, ឯកសារ ICTR-2001-64-A, សាលដីកា, ថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០០៦ (“សាលដីកាលើករណីរបស់ *Gacumbitsi*”), កថាខណ្ឌ ៨៦, *ដោយធ្វើការដកស្រង់ពីសាលដីកាលើករណីរបស់* *Ntakirutimana*, កថាខណ្ឌ ៥២២។

52 *សាលក្រម ឌុច*, កថាខណ្ឌ ៣៧៤ ដល់ ៨០។

53 សាលដីកា ឌុច, កថាខណ្ឌ ២៧៥ ដល់ ៧៧។

54 លក្ខន្តិកៈនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ, មាត្រា ៧(១)(ជ)។

55 *សូមមើល* ញត្តិផ្សេងទៀតស្តីពីព្រំដែនកម្រិតលទ្ធភាពអនុវត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ កថាខណ្ឌ ២៣, បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ ២២៦ ដល់២៩។

56 ក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦, មាត្រា ៦។

IMT (ខ)ធម្មនុញ្ញឆ្នាំ ១៩៤៦ របស់តុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា ("IMFTE"); (គ) គោលការណ៍ Nuremberg ឬ (ឃ)សេចក្ដីព្រាងក្រមស្ដីពីបទល្មើសប្រឆាំងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ ឆ្នាំ ១៩៥៤។ ការមិនបញ្ចូលការផ្លាស់ប្ដូរទីលំនៅដោយបង្ខំទៅក្នុងលិខិតុបករណ៍ទាំងនេះថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិបង្ហាញថា វាមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ទេ។

19. ធាតុផ្សំនៃការផ្លាស់ប្ដូរទីកន្លែងដោយបង្ខំដោយចាត់ទុកថា ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមិនត្រូវបានលើកមកបញ្ជាក់ដោយអង្គជំនុំជម្រះណាមួយរបស់ អ.វ.ត.ក ទេ។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចថា ខ្លួនមានយុត្តាធិការលើការផ្លាស់ប្ដូរទីកន្លែងដោយបង្ខំនោះ អង្គជំនុំជម្រះសាលាដំបូងត្រូវតែមានធាតុផ្សំដូចតទៅ ៖ **ក.**ត្រូវមានការផ្លាស់ប្ដូរទីកន្លែងមនុស្សដោយបង្ខំ **ខ.**ផ្លាស់ប្ដូរពីតំបន់ដែលពួកគេមានវត្តមានស្របច្បាប់ **គ.**អវត្តមាននៃមូលហេតុដែលអនុញ្ញាតដោយច្បាប់អន្តរជាតិ[57] **ឃ.**ចេតនាដកជនរងគ្រោះចេញ ដែលបង្ហាញពីបំណងថា ជនរងគ្រោះនោះមិនអាច ឬនឹងមិនត្រឡប់មកវិញរហូត[58]។ ការផ្លាស់ប្ដូរទីកន្លែងដោយបង្ខំមិនមែនជាអនុផ្នែកនៃ "ការនិរទេស"។ មិនដូចគ្នានឹងការផ្លាស់ប្ដូរទីកន្លែងដោយបង្ខំទេ "ការនិរទេស" តម្រូវឱ្យមានការឆ្លងព្រំដែនរបស់រដ្ឋ បើតាមច្បាប់ *(de jure)* ឬនៅក្នុងកាលៈទេសៈខ្លះ បើតាមហេតុ *(de facto)* តម្រូវថាបានឆ្លងកាត់ព្រំដែន[59]។

---

[57] *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង* *Krnojelac*, ឯកសារ IT-97-25-A, សាលដីកា, ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣ ("សាលដីកាលើករណីរបស់ *Krnojelac*"), កថាខណ្ឌ ២២២; *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង* *Perišić*, ឯកសារ IT-04-81-T, សាលក្រម, ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១១, កថាខណ្ឌ ១១៣; *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង* *Krajišnik*, ឯកសារ IT-00-39-T, សាលក្រម, ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៦ ("សាលក្រមលើករណីរបស់ *Krajišnik*"), កថាខណ្ឌ ៧២៣។

[58] *សូមមើល* សាលដីកាលើករណីរបស់ *Krnojelac*, *មតិយោបល់ដោយឡែករបស់ចៅក្រម* Schomburg, កថាខណ្ឌ ១៦; *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង* *Blagojević & Jokić*, ឯកសារ IT-02-60-T, សាលក្រម, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ("សាលក្រមលើករណីរបស់ *Blagojević & Jokić*"), កថាខណ្ឌ ៦០១; *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង* *Naletilić & Martinović*, ឯកសារ IT-98-34-T, សាលក្រម, ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣, កថាខណ្ឌ ៥២១។

[59] *សូមមើល*សាលដីកាលើករណីរបស់ *Stakić*, កថាខណ្ឌ ២៧៨, កថាខណ្ឌ ២៨៩; *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង* *Brđanin*, ឯកសារ IT-99-36-T, សាលក្រម, ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០០៤ ("សាលក្រមលើករណីរបស់ *Brđanin*"), កថាខណ្ឌ ៥៤២។ *សូមមើលផងដែរ*សាលក្រមលើករណីរបស់ *Blagojević & Jokić*, កថាខណ្ឌ ៥៩៧ ដល់ ៦០១, កថាខណ្ឌ ៦២៩, សម្រាប់ការពិភាក្សាលើការលើកលែងពីការហាមមិនឱ្យធ្វើការផ្លាស់ប្ដូរទីលំនៅដោយបង្ខំនាសម័យបច្ចុប្បន្ន នៅពេលមិនត្រូវបានអនុវត្តដោយផ្អែកលើមូលដ្ឋានដែលទទួលស្គាល់ក្រោមច្បាប់អន្តរជាតិ។

20. ការជម្លៀសអាចត្រូវបានអនុញ្ញាត ក្នុងករណីមានមូលហេតុមនុស្សធម៌ក្នុងស្ថានភាពជម្លោះប្រដាប់អាវុធ។ រោគរាតត្បាត គ្រោះធម្មជាតិ ឬអត្ថិភាពនៃស្ថានភាពរស់នៅដែលជាទូទៅមិនអាចការពារបាន និងគម្រាមកំហែងដល់ជីវិតអាចជាហេតុស្របច្បាប់ដើម្បីធ្វើការផ្លាស់ប្តូរទីកន្លែងដោយបង្ខំ ក្នុងអំឡុងពេលមានជម្លោះ[60]។ អនុសញ្ញាទីក្រុងហ្សឺណែវទីបួន និងពិធីសារបន្ថែម II អនុញ្ញាតឲ្យធ្វើការជម្លៀសប្រជាជនក្នុងចំនួនណាមួយ ឬក៏ប្រជាជនទាំងអស់ "ប្រសិនសន្តិសុខរបស់ប្រជាជន ឬមូលហេតុយោធាចាំបាច់តម្រូវឲ្យមានការធ្វើជម្លៀសនោះ"[61] ឧទាហរណ៍ នៅពេលតំបន់មួយស្ថិតក្នុងសភាពគ្រោះថ្នាក់ ដោយសារតែមានប្រតិបត្តិការយោធា ឬតំបន់នោះប្រឈមទៅនឹងការទម្លាក់គ្រាប់បែកធ្ងន់ធ្ងរ ឬនៅពេលដែលវត្តមានរបស់ប្រជាជននៅក្នុងតំបន់មួយអាចរាំងស្ទះដល់ប្រតិបត្តិការយោធា[62]។

### ៥. ការបាត់ខ្លួនបុគ្គលដោយបង្ខំ

21. អង្គជំនុំជម្រះសាលាដំបូងពុំមានយុត្តាធិការក្នុងការធ្វើសវនាការលើបទចោទនានា នៃការបាត់ខ្លួនដោយបង្ខំឡើយ[63] ពីព្រោះការបាត់ខ្លួនបុគ្គលដោយបង្ខំនេះមិនត្រូវបានចែងច្បាស់លាស់នៅក្នុងមាត្រា ៥ ឡើយ។ ដោយតុលាការកម្ពុជាផ្អែកលើប្រព័ន្ធច្បាប់ស៊ីវិលជាមូលដ្ឋាននោះ អ.វ.ត.ក មានយុត្តាធិការទៅលើតែឧក្រិដ្ឋទាំងឡាយណាដែលមានចែងយ៉ាងច្បាស់ប៉ុណ្ណោះ[64]។ ការបាត់ខ្លួនបុគ្គលដោយបង្ខំមិនមែនជាឧក្រិដ្ឋ

---

[60] ពិធីសារបន្ថែមទៅនឹងអនុសញ្ញាទីក្រុងហ្សឺណែវ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ និងមានទំនាក់ទំនងទៅនឹងការការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ (ពិធីសារ II), ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ១៩៧៧ ("ពិធីសារបន្ថែម II"), បទអត្ថាធិប្បាយ, ទំព័រ ១៤៧៣; សាលក្រមលើករណីរបស់ *Blagojević & Jokić*, កថាខណ្ឌ ៦០០។ *សូមមើលផងដែរ* សាលដីកាលើករណីរបស់ *Stakić*, កថាខណ្ឌ ២៨៧; *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Popović *និងអ្នកផ្សេងៗទៀត.*, ឯកសារ IT-05-88-T, សាលក្រម, ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ ("សាលក្រមលើករណីរបស់ *Popović* "), កថាខណ្ឌ ៩០៣។

[61] អនុសញ្ញា (IV) ទាក់ទងនឹងការការពារជនស៊ីវិលក្នុងពេលសង្គ្រាម, ទីក្រុងហ្សឺណែវ, ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩, មាត្រា ៤៩; ពិធីសារបន្ថែម, មាត្រា ១៧។ *សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krstić*, ឯកសារ IT-98-33-T, សាលក្រម, ថ្ងៃទី ២ ខែ សីហា ឆ្នាំ ២០០១, កថាខណ្ឌ ៥២៤; សាលក្រមលើករណីរបស់ *Krajišnik*, កថាខណ្ឌ ៧២៥; សាលក្រមលើករណីរបស់ *Blagojević & Jokić*, កថាខណ្ឌ ៥៩៨។

[62] សាលក្រមលើករណីរបស់ *Popović*, កថាខណ្ឌ ៩០១។

[63] *សូមមើល*ចម្លើយតបទៅនឹងសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីស្តីពីការបាត់ខ្លួនបុគ្គលដោយបង្ខំ, កថាខណ្ឌ ២១ ដល់ ២៨; ញត្តិផ្សេងៗទៀត ស្តីពីព្រំដែនកម្រិតលទ្ធភាពអនុវត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, កថាខណ្ឌ ២២; បណ្តឹងសាទុក្ខប្រឆាំងដីកាដំណោះស្រាយ, កថាខណ្ឌ ២៣០ ដល់ ៣១។

[64] *សូមមើល*ក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦, មាត្រា ៦។

កម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬច្បាប់កម្ពុជាពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ទេ។ លិខិតុបករណ៍អន្តរជាតិទាំងអស់ដែលទាក់ទងនឹងការបាត់ខ្លួនបុគ្គលដោយបង្ខំ បានកើតក្រោយពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩[65]។ គ្មានលិខិតុបករណ៍ណាមួយក្នុងចំណោមលិខិតុបករណ៍ទាំងនេះបំពេញលក្ខខណ្ឌនៃការអនុវត្តរបស់រដ្ឋ ឬសច្ចធារណ៍ធម្មានុរូប (*opinio juris*)[66]។ ដូច្នេះ គ្មានលិខិតុបករណ៍ទាំងនេះដែលបំពេញលក្ខខណ្ឌក្នុងការអនុវត្តការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ជាបុគ្គលលើការបាត់ខ្លួនបុគ្គលដោយបង្ខំពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៥ ទេ[67]។

22. ធាតុផ្សំនៃការបាត់ខ្លួនបុគ្គលដោយបង្ខំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មិនត្រូវបានលើកមកបញ្ជាក់ដោយអង្គជំនុំជម្រះណាមួយរបស់ អ.វ.ត.ក ទេ។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចថា ខ្លួនមានយុត្តាធិការលើការផ្លាស់ប្តូរទីកន្លែងដោយបង្ខំនោះ អង្គជំនុំជម្រះសាលាដំបូងត្រូវតែមានធាតុផ្សំដូចតទៅ ៖ **ក.**ជនរងគ្រោះត្រូវតែបានបិទសិទ្ធិសេរីភាព តាមរយៈការចាប់ខ្លួន ការឃុំខ្លួន ឬអំពើផ្សេងៗទៀត **ខ.**ការបាត់ខ្លួនរបស់ជនរងគ្រោះត្រូវតែបានធ្វើឱ្យជនរងគ្រោះនោះ ស្ថិតនៅខាងក្រៅការការពារពីច្បាប់ ដូចជា ជនរងគ្រោះនោះត្រូវបានបដិសេធនូវដំណោះស្រាយលើការទូទាត់សងផ្លូវច្បាប់ជាធរមាន និងការ

---

[65] *សូមមើល* U.N.G.A Res. 47/133 សេចក្តីប្រកាសស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនបុគ្គលដោយបង្ខំ, ឯកសារអង្គការសហប្រជាជាតិ A/47/49, ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩២; លក្ខន្តិកៈនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ, ឆ្នាំ ១៩៩៨ (ដែលបានចូលជាធរមាន នៅឆ្នាំ ២០០២); អនុសញ្ញាអន្តរជាតិសម្រាប់ការការពារជនគ្រប់រូបពីការបាត់ខ្លួនបុគ្គលដោយបង្ខំ, ឯកសារអង្គការសហប្រជាជាតិ A/61/488, ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៦ និងអនុសញ្ញាអន្តរអាមេរិកស្តីពីការបាត់ខ្លួនបុគ្គលដោយបង្ខំ, ៣៣ ILM ១៤២៩, ឆ្នាំ ១៩៩៤។

[66] *សូមមើល* សារណា, កថាខណ្ឌ ៤ អំពីនិយមន័យនៃការអនុវត្តរបស់រដ្ឋ និងសច្ចធារណ៍ធម្មានុរូប (*opinio juris*)។ បើទោះបីជាមានការអនុម័តសេចក្តីថ្លែងការណ៍នៃមហាសន្និបាតអង្គការសហប្រជាជាតិ ស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនបុគ្គលដោយបង្ខំ នៅខែ ធ្នូ ឆ្នាំ ១៩៩២ ក៏ដោយ ក៏មានរដ្ឋតិចតួចប៉ុណ្ណោះដែលបានចាត់វិធានការណ៍ជាក់លាក់មួយចំនួនដើម្បីអនុវត្តតាមបទដ្ឋាននៃសេចក្តីថ្លែងការណ៍នេះ។ អនុសញ្ញាអន្តរអាមេរិកស្តីពីការបាត់ខ្លួនបុគ្គលដោយបង្ខំត្រូវបានផ្តល់សច្ចាប័នដោយសមាជិកចំនួន ១៤ ក្នុងចំណោមសមាជិកចំនួន ៣៤ នៃអង្គការរដ្ឋអាមេរិក។ នេះគឺជាភស្តុតាងយ៉ាងលំបាកមួយនៃការអនុវត្តរបស់រដ្ឋដែលមានលក្ខណៈស៊ីសង្វាក់គ្នាដើម្បីកំណត់ជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ បញ្ជីឈ្មោះរដ្ឋដែលបានផ្តល់សច្ចាប័ន *អាចរកឃើញនៅ* http://www.oas.org/juridico/english/sigs/a-60.html។

[67] សាស្ត្រាចារ្យ Cassese បានសម្រេចស្រដៀងគ្នានេះដែរថា ការបាត់ខ្លួនបុគ្គលដោយបង្ខំ មិនមែនជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ទេ។ *សូមមើល* ANTONIO CASSESE, INTERNATIONAL CRIMINAL LAW 113 (2nd ed. OUP 2008)។

ធានាពីនីតិវិធី និង **គ.**ចារីត្រូវតែបដិសេធមិនផ្តល់ព័ត៌មានទាក់ទងនឹងជោគវាសនា ឬកន្លែងរស់នៅរបស់ជនរងគ្រោះ ឬដឹងពីការដកហូតសិទ្ធិសេរីភាព[68]។

### ៦. អំពើអមនុស្សធម៌ផ្សេងៗទៀត

23. អង្គជំនុំជម្រះសាលាដំបូងពុំមានយុត្តាធិការលើ "អំពើអមនុស្សធម៌ផ្សេងៗទៀត"[69]។ អង្គជំនុំជម្រះសាលាដំបូងមានការភ័ន្តច្រឡំក្នុងការអះអាងពីយុត្តិសាស្ត្រ[70]។

24. បើទោះបីជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ត្រូវបានកំណត់ជាប្រភេទឧក្រិដ្ឋកម្មមួយដែលមានចែងនៅក្នុងមាត្រា ៥ ក៏ដោយ ក៏បទប្បញ្ញត្តិនេះមិនបានបញ្ជាក់ឱ្យបានច្បាស់ថាតើអំពើដែលកំណត់ថាជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ជាអ្វីនោះទេ។ ដោយតុលាការកម្ពុជាផ្អែកលើប្រព័ន្ធច្បាប់ស៊ីវិលជាមូលដ្ឋាននោះ អ.វ.ត.ក មានយុត្តាធិការទៅលើតែឧក្រិដ្ឋទាំងឡាយណា ដែលមានចែងយ៉ាងច្បាស់ប៉ុណ្ណោះ[71]។ កង្វះនៃការកំណត់ឱ្យបានច្បាស់លាស់នូវ "អំពើអមនុស្សធម៌ផ្សេងៗទៀត" នេះអាចរំលោភលើ

---

[68] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* *Gotovina*, ឯកសារ IT-06-90-T, សាលក្រម, ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ២០១១ ("សាលក្រមលើករណីរបស់ *Gotovina*"), កថាខណ្ឌ ១៨៣១ ដល់ ៣២, កថាខណ្ឌ ១៨៣៧។

[69] *សូមមើល*ញត្តិផ្សេងទៀតស្តីពីព្រំដែនកម្រិតលទ្ធភាពអនុវត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, កថាខណ្ឌ ១៣ ដល់ ១៥; បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ ២២០។

[70] *សូមមើល* សាលក្រម ឌុច , កថាខណ្ឌ ៣៦៧ ដល់ ៧១។

[71] *សូមមើល* ក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦, មាត្រា ៦។ អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានបញ្ជាក់ថា "ឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ដែលមានលក្ខណៈទូលំទូលាយអាចនាំឱ្យមានការបារម្ភចំពោះការរំលោភបំពានដែលអាចកើតមានលើគោលការណ៍ *គ្មានបទល្មើស បើគ្មានច្បាប់ចែង*"។ សាលដីកាលើករណីរបស់ *Kordić & Čerkez*, កថាខណ្ឌ ១១៧។ អង្គជំនុំជម្រះសាលាដំបូងក្នុងករណី *Stakić* បានបញ្ជាក់ថា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ដែលជាឧក្រិដ្ឋកម្មមួយប្រភេទនោះ "អាចត្រូវបានចាត់ទុកថាពុំមានភាពច្បាស់លាស់, ភាពល្អិតល្អន់ និងភាពប្រាកដប្រជាគ្រប់គ្រាន់" ដែលកត្តានេះអាចជាការរំលោភដល់គោលការណ៍នៃភាពច្បាស់លាស់។ *សូមមើល រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* *Stakić*, ឯកសារ IT-97-24-T, សេចក្តីសម្រេចលើញត្តិសុំឱ្យសម្រេចឱ្យរួចផុតពីបទចោទ អនុលោមតាមវិធាន ៩៨*ស្ទួន*, ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០២, កថាខណ្ឌ ១៣១។ សាលដីកាលើករណីរបស់ *Stakić*, កថាខណ្ឌ ៣១៥, ដែលបានសម្រេចច្រានចោលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងសម្រេចថា "អំពើអមនុស្សធម៌ផ្សេងៗទៀត" គឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល ដូចជា អ.វ.ត.ក, សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងករណីរបស់ *Kordić & Čerkez* និងអង្គជំនុំជម្រះសាលាដំបូងក្នុងករណីរបស់ *Stakić* គឺជាការបកស្រាយយ៉ាងត្រឹមត្រូវ។

គោលការណ៍*គ្មានច្បាប់ គឺគ្មានទោស (nullum crimen sine lege)*[72]។ ពាក់ព័ន្ធនឹងបរិបទជាក់លាក់នៃការផ្លាស់ប្តូរទីកន្លែងដោយបង្ខំនេះ បើទោះបីជាមានការសន្មតថាបានដឹងពីទស្សនៈនេះក៏ដោយ (ចំណុចនេះត្រូវបានបញ្ចូលទៅក្នុងច្បាប់ប្រល័យពូជសាសន៍ ក្រោមមាត្រា ៤) ក៏ដោយ ក៏អ្នកធ្វើសេចក្តីព្រាងនៃច្បាប់ស្តីពីការបង្កើតមិនបានបញ្ចូលចំណុចនេះទៅក្នុងបទល្មើសដែលបានចែងនៅក្នុងមាត្រា ៥ (មិនដូចគ្នានឹងការនិរទេស)ទេ[73]។ ការផ្លាស់ប្តូរទីកន្លែងដោយបង្ខំមិនគួរចាត់ទុកថាជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ឡើយ។

---

[72] កង្វះខាតយ៉ាងខ្លាំងលើភាពជាក់លាក់នៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ត្រូវបានបង្ហាញតាមរយៈវិធីសាស្ត្រមិនស៊ីសង្វាក់គ្នាក្នុងការបកស្រាយឧក្រិដ្ឋកម្មប្រភេទនេះនៅឯងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដែលត្រូវបានវាយតម្លៃថាបានរំលោភដល់គោលការណ៍នៃភាពច្បាស់លាស់ ប៉ុន្តែបែរជាបានបង្កើតជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ នៅក្នុងករណី *Kupreškić*, បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ "មានជាអាទិ៍សិទ្ធិមនុស្សដែលបានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ឆ្នាំ ១៩៤៨ និងកតិកាសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស ឆ្នាំ ១៩៦៦" ត្រូវបានកំណត់ថាជាការចែងដែលអាចប្រមើមើលឃើញនូវអ្វីៗដែលបង្កើតបានជា "អំពើអមនុស្សធម៌ផ្សេងៗទៀត"។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kupreškić et al.*, ឯកសារ IT-95-16-T, សាលក្រម, ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០០ ("សាលក្រមលើករណីរបស់ *Kupreškić*"), កថាខណ្ឌ ៥៦៦។ វិធីសាស្ត្រនេះត្រូវបានរិះគន់ដោយអង្គជំនុំជម្រះសាលាដំបូងលើរឿងក្តីរបស់ *Stakić* ដែលថា "'ការអនុវត្តគោលការណ៍ *គ្មានបទល្មើស បើគ្មានច្បាប់ចែង (nullum crimen sine lege)* តម្រូវថា តុលាការអន្តរជាតិនេះត្រូវអនុវត្តវិធាននៃច្បាប់មនុស្សធម៌អន្តរជាតិដែលច្បាស់ណាស់វាជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់'។ អាស្រ័យហេតុនេះហើយ ទើបអង្គជំនុំជម្រះសាលាដំបូងនេះស្ទាក់ស្ទើរក្នុងការប្រើប្រាស់លិខិតុករណ៍សិទ្ធិមនុស្សដូចនេះដោយស្វ័យប្រវត្តិថា ជាមូលដ្ឋាននៃបទដ្ឋានច្បាប់ព្រហ្មទណ្ឌ ដូចជា ករណីមួយដែលចែងនៅក្នុងមាត្រា ៥ (ឈ) នៃលក្ខន្តិកៈ.... *បទដ្ឋាននៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិត្រូវតែផ្តល់ដល់អង្គជំនុំជម្រះសាលាដំបូងនូវឧបករណ៍សមរម្យមួយសម្រាប់ជាមូលដ្ឋានក្នុងការថ្លឹងថ្លែងការប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលបានចោទប្រកាន់សម្រាប់គោលបំណងនៃមាត្រា ៥(ឈ)ដើម្បីឲ្យបុគ្គលគ្រប់រូបដឹងថាអ្វីជាការប្រព្រឹត្តដែលគេអនុញ្ញាត ហើយអ្វីដែលគេមិនអនុញ្ញាត*'។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Stakić, ឯកសារ IT-97-24-T, សាលក្រម, ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៣ ("សាលក្រមលើករណីរបស់ *Stakić*"), កថាខណ្ឌ ៧២១ (មានបន្ថែមការបញ្ជាក់)។ *សូមមើលផងដែរ*សាលក្រមលើករណីរបស់ *Blagojević & Jokić*, កថាខណ្ឌ ៦២៥។

[73] ដូចគ្នានឹងកំណត់សម្គាល់របស់សាស្ត្រាចារ្យ Schabas ថា ៖ "អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Stakić* បានបញ្ជាក់ថា អ្នកធ្វើសេចក្តីព្រាងលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី មិនបានដឹងអំពីទស្សនៈនៃការផ្លាស់ប្តូរទីកន្លែងដោយបង្ខំទេ ពីព្រោះពួកគេបានដាក់បញ្ចូលធាតុផ្សំនេះនៅក្នុងមាត្រា ៤ ថាជាជាអំពើមួយក្នុងចំណោមអំពើប្រល័យពូជសាសន៍ដែលអាចផ្តន្ទាទោសបាន (ការជម្លៀសកុមារដោយបង្ខំ ពីក្រុមមួយទៅក្រុមមួយទៀត)។ ដូច្នេះ 'បញ្ហាដែលថា ការផ្លាស់ប្តូរទីកន្លែងដោយបង្ខំមិនមាននិយាយច្បាស់លាស់នៅក្នុងមាត្រា ៥ (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ) ផ្តល់ការគាំទ្របន្ថែមក្នុងការមិនចាត់ទុកថា វាជាផ្នែកមួយនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត," ដែលខុសពីការនិរទេស ...'។ ការយល់ឃើញរបស់អង្គជនុំជម្រះសាលាដំបូងលើរឿងក្តីរបស់ *Stakić* គឺជាគ្រាន់តែជាបង្ហាញឲ្យឃើញពីអំពីការបារម្ភមួយក្នុងចំណោមចៅក្រមនៅក្នុងតុលាការនេះ ចំពោះលក្ខណៈមិន

25. ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចថា ខ្លួនមានយុត្តាធិការលើ "អំពើអមនុស្សធម៌ផ្សេងៗទៀត" នោះ អង្គជំនុំជម្រះសាលាដំបូងត្រូវតែមានធាតុផ្សំដូចតទៅ ៖ **ក.**អំពើសកម្ម ឬអកម្ម មានភាពធ្ងន់ធ្ងរស្រដៀងគ្នាយ៉ាងច្រើនទៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[74] **ខ.**ជនរងគ្រោះទទួលរងការឈឺចាប់យ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ឬផ្លូវចិត្ត[75] ឬការវាយប្រហារដ៏ធ្ងន់ធ្ងរទៅលើសេចក្ដីថ្លៃថ្នូរជាមនុស្សជាតិរបស់ជនរងគ្រោះ[76] **គ.**ការឈឺចាប់បណ្ដាលមកពីអំពើសកម្ម ឬអកម្មរបស់ចារី[77] និង **ឃ.**ចារីមានបំណងបង្កឲ្យមានឲ្យព្យសនកម្មលើរាងកាយ ឬផ្លូវចិត្ត ឬធ្វើការវាយប្រហារធ្ងន់ធ្ងរលើភាពថ្លៃថ្នូរជាមនុស្សជាតិ ឬចារីដឹងថា អំពើរបស់ខ្លួនទំនងជាបង្កឲ្យមានការឈឺចាប់ធ្ងន់ធ្ងរលើរូបរាងកាយ ឬផ្លូវចិត្ត ឬការវាយប្រហារធ្ងន់ធ្ងរលើភាពថ្លៃថ្នូរជាមនុស្សជាតិ[78]។ ដើម្បីបង្ហាញថា ការផ្លាស់ប្ដូរទីលំនៅដោយបង្ខំ ឬការបាត់ខ្លួនបុគ្គលដោយបង្ខំជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" អង្គជំនុំជម្រះសាលាដំបូង ត្រូវតែអនុវត្ត ៖ **ក.**លក្ខខណ្ឌ*ពាក់ព័ន្ធនឹង* ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ **ខ.**ធាតុផ្សំនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត"; និង **គ.**ធាតុផ្សំនៃបទល្មើសដែលជាដើមចម[79]។

## II. ទម្រង់នៃការទទួលខុសត្រូវ ÷ ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ÷ មាត្រា ២៩

### ក. ការរៀបចំផែនការ

ច្បាស់លាស់នៃប្រភេទ អំពើអមនុស្សធម៌ផ្សេងៗទៀត…" WILLIAM SCHABAS, តុលាការព្រហ្មទណ្ឌអន្តរជាតិ តុលាការ ICTY, តុលាការ ICTR, តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន 224 (CUP 2006)។

[74] សាលក្រម ឌុច , កថាខណ្ឌ ៣៦៧។

[75] *ដូចខាងលើ*, កថាខណ្ឌ ៣៦៨។

[76] *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង* *Vasiljević*, ឯកសារ IT-98-32-A, សាលដីកា, ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៤ ("សាលដីកាលើករណីរបស់ *Vasiljević*"), កថាខណ្ឌ ១៦៥; *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង* *Bagosora*, ICTR-98-41-T, សាលក្រម, ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨, កថាខណ្ឌ ២២១៨។

[77] សាលក្រម ឌុច , កថាខណ្ឌ ៣៦៨។

[78] *ដូចខាងលើ*, កថាខណ្ឌ ៣៧១។

[79] *សូមមើល*សាលក្រមលើករណីរបស់ *Blagojević & Jokić*, កថាខណ្ឌ ៦២៣ ដល់ ៣០ (ការផ្លាស់ប្ដូរទីកន្លែងដោយបង្ខំដោយចាត់ទុកថាជា "អំពើអមនុស្សធម៌ផ្សងៗទៀត"); សាលក្រមលើករណីរបស់ *Kupreškić*, កថាខណ្ឌ ៥៦៦ (ការបាត់ខ្លួនបុគ្គលដោយបង្ខំដោយចាត់ទុកថាជា "អំពើអនុស្សធម៌ផ្សេងៗទៀត"); សាលក្រមលើករណីរបស់ *Gotovina*, កថាខណ្ឌ ១៨៣៨ (ការបាត់ខ្លួនដោយបង្ខំដោយចាត់ទុកថាជា "អំពើអមនុស្សធម៌ផ្សេងៗទៀត")។ *សូមមើលផងដែរ* សាលក្រម ឌុច , កថាខណ្ឌ ៣៧០។

26. ការរៀបចំផែនការធ្វើឡើង នៅពេល **ក.**បុគ្គលម្នាក់ ឬច្រើននាក់បានរៀបចំប្រព្រឹត្តអំពើឧក្រិដ្ឋមួយ ឬច្រើន **ខ.**ក្រោយមក មានការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះ **គ.**ការរៀបចំផែនការនោះរួមចំណែកយ៉ាងសំខាន់ ក្នុងការឈានទៅប្រព្រឹត្តឧក្រិដ្ឋកម្ម និង **ឃ.**ជនជាប់ចោទត្រូវតែមានចេតនាក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬបានដឹងអំពីភាពសំខាន់ដែលថា ឧក្រិដ្ឋកម្មទំនងនឹងត្រូវប្រព្រឹត្ត នៅពេលអនុវត្តផែនការនោះ[80]។

**ខ. ការញុះញង់**

27. ការញុះញង់កើតមាន នៅពេល **ក.**បុគ្គលម្នាក់ប្រព្រឹត្តអំពើសកម្ម ឬអកម្ម តាមវិធីមួយដែលជំរុញបុគ្គលផ្សេងទៀតឲ្យប្រព្រឹត្តឧក្រិដ្ឋកម្ម **ខ.**ឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្ត **គ.**អំពើសកម្ម ឬអកម្មរួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តឧក្រិដ្ឋកម្ម **ឃ.**ជនជាប់ចោទបានប្រព្រឹត្តដោយចេតនា ឬដោយដឹងអំពីភាពសំខាន់ដែលថា ឧក្រិដ្ឋកម្មទំនងនឹងត្រូវប្រព្រឹត្ត នៅពេលអនុវត្តការញុះញង់នោះ[81]។

**គ. ការបញ្ជា**

28. ការបញ្ជាកើតមាន នៅពេល ៖ **ក.**បុគ្គលម្នាក់ក្នុងឋានៈជាអ្នកមានអំណាច **ខ.**បង្គាប់បុគ្គលផ្សេងទៀតឲ្យប្រព្រឹត្តឧក្រិដ្ឋកម្ម **គ.**ឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្ត **ឃ.**ការចេញបទបញ្ជាដែលរួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តឧក្រិដ្ឋកម្ម និង **ង.**ជនជាប់ចោទបានប្រព្រឹត្តដោយចេតនា ឬដោយដឹងអំពីភាពសំខាន់ដែលថា ឧក្រិដ្ឋកម្មទំនងនឹងត្រូវប្រព្រឹត្ត នៅពេលអនុវត្តការបញ្ជានោះ[82]។

**ឃ. ការជួយ និងទំនុកបម្រុង**

29. ការជួយ និងទំនុកបម្រុងកើតមាន នៅពេល **ក.**ជនជាប់ចោទផ្ដល់ជំនួយ លើកទឹកចិត្ត ឬគាំទ្រផ្លូវចិត្តជាក់ស្ដែងដល់ចារី **ខ.**ឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្ត **ខ.**ការជួយ ការលើកទឹកចិត្ត ឬការគាំទ្រផ្លូវចិត្តជាក់ស្ដែងរបស់ជនជាប់ចោទ មានឥទ្ធិពលយ៉ាងសំខាន់ដល់ការប្រព្រឹត្តឧក្រិដ្ឋកម្ម និង **ឃ.**ជនជាប់ចោទបានដឹងថា ឧក្រិដ្ឋកម្មមួយប្រហែលជាត្រូវប្រព្រឹត្ត ហើយបានដឹងថា ទង្វើរបស់ខ្លួនបានជួយដល់ការប្រព្រឹត្តឧក្រិដ្ឋកម្មនោះ[83]។ អំពើអកម្មរបស់ជនជាប់ចោទ *អាច* ជាការជួយ និងទំនុកបម្រុង *ប្រសិនបើ* អំពើអកម្មនោះរួម

[80] សាលក្រម ឌុច , កថាខណ្ឌ ៥១៨ ដល់ ១៩។

[81] *ដូចខាងលើ*, កថាខណ្ឌ ៥២២ ដល់ ២៤។

[82] *ដូចខាងលើ*, កថាខណ្ឌ ៥២៧ ដល់ ២៨។

[83] *ដូចខាងលើ*, កថាខណ្ឌ ៥៣២ ដល់ ៣៥។

ចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬប្រសិនបើជនជាប់ចោទ មានភារកិច្ចផ្លូវច្បាប់ច្បាស់លាស់ក្នុងប្រព្រឹត្តបទឧក្រិដ្ឋ ឬខកខានមិនបានប្រព្រឹត្ត[84]។

**ង. ការប្រព្រឹត្ត**

30. ការប្រព្រឹត្តកើតមាន នៅពេល **ក.**ជនជាប់ចោទប្រព្រឹត្តឧក្រិដ្ឋកម្មដោយផ្ទាល់ ឬមានអំពើអកម្មដែលខ្លួនមានតួនាទីផ្លូវច្បាប់ក្នុងការបំពេញភារកិច្ចនោះ និង **ខ.**ជនជាប់ចោទបានប្រព្រឹត្តដោយចេតនា ឬដោយដឹងអំពីភាពសំខាន់ដែលថាឧក្រិដ្ឋកម្មទំនងនឹងត្រូវប្រព្រឹត្ត ដោយសារតែសកម្មភាពរបស់ខ្លួន[85]។

**ច. សហឧក្រិដ្ឋកម្មរួម**

31. សហឧក្រិដ្ឋកម្មរួម មិនមែនជាទម្រង់នៃការទទួលខុសត្រូវឧក្រិដ្ឋកម្មដែលមានការទទួលស្គាល់ នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ទេ[86]។ អង្គបុរេជំនុំជម្រះមានការភ័ន្តច្រឡំក្នុងការសម្រេចថា ទម្រង់ ("សហឧក្រិដ្ឋកម្មរួម I") ជាមូលដ្ឋាន និងទម្រង់ ("សហឧក្រិដ្ឋកម្មរួម II") ជាលក្ខណៈប្រព័ន្ធ អាចយកមកអនុវត្តបាន[87]។ អង្គបុរេជំនុំជម្រះបានសម្រេចយ៉ាងត្រឹមត្រូវថា ទម្រង់ ("សហឧក្រិដ្ឋ

---

[84] សាលដីកាលើករណីរបស់ *Blaškić*, កថាខណ្ឌ ៤៧; *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Mrkšić*, ឯកសារ IT-95-13/1-A, សាលដីកា, ថ្ងៃទី ៥ ឧសភា ឆ្នាំ ២០០៩, កថាខណ្ឌ ៨១ ដល់ ៨២; *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Brđanin*, ឯកសារ IT-99-36-A, សាលដីកា, ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០០៧ ("សាលដីកាលើករណីរបស់ *Brđanin*"), កថាខណ្ឌ ២៧៤។

[85] សាលក្រម ឌុច , កថាខណ្ឌ ៤៧៩ ដល់ ៤៨១។

[86] *សូមមើល* សំណើប្រឆាំងនឹងការអនុវត្តទ្រឹស្តីសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ ១៧ ដល់ ២៩; សំណើជាបន្ទាន់របស់លោក អៀង សារី សុំដាក់អំណះអំណាងស្តីពីការអនុវត្តការទទួលខុសជាទម្រង់សហឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច", ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨, ឯកសារ D99/3/6; ការសង្កេតបន្ថែមលើសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ ៣០ ដល់ ៥៤; បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ កសចស ស្តីពីសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ ៣៦ ដល់ ៥៨; ញត្តិផ្សេងទៀតស្តីពីព្រំដែនកម្រិតលទ្ធភាពអនុវត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, កថាខណ្ឌ ១៣ ដល់ ១៥; បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ ២៤៩ ដល់ ៦៣; ឆ្លើយតបទៅនឹងចម្លើយតបរបស់ *Advocats Sans Frontières* ចំពោះបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ ១៩ ដល់ ១៩; ចម្លើយតបទៅនឹងសំណើរបស់ ក.ស.ព ពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួមទម្រង់ III, ឯកសារ E100/2។

[87] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតស្តីពីសហឧក្រិដ្ឋម្មរួម, ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ ("សេចក្តីសម្រេចរបស់ អបជ លើសហឧក្រិដ្ឋកម្មរួម"), ឯកសារ D47/15/9; សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម, ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១, ឯកសារ E100/6 ("សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម")។ *សូមមើលផងដែរ* សាលក្រម ឌុច, កថាខណ្ឌ ៥១១។

កម្មវិធី III") ដែលត្រូវបានពង្រីកបន្ថែម មិនអាចយកមកអនុវត្តបានទេ ពីព្រោះទម្រង់នេះ ពុំត្រូវបានចែង នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[88]។

**១. អត្ថិភាពនៃសហឧក្រិដ្ឋកម្មរួម អនុលោមតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩**

32. សហឧក្រិដ្ឋកម្មរួមមិនធ្លាប់បានក្លាយជាទម្រង់មួយនៃការទទួលខុសត្រូវទូទៅ និងស៊ីសង្វាក់គ្នា ក្នុងការអនុវត្តរបស់រដ្ឋឡើយ។ រឿងក្តី *Tadić* បានពឹងផ្អែកលើករណីតិចតួចខ្លាំងណាស់ដើម្បីគាំទ្រដល់អត្ថិភាពនៃការអនុវត្តដូចនេះ[89] ក្នុងនោះ សហឧក្រិដ្ឋកម្មរួម I មានចំនួន ៦ ករណី[90] និងសហឧក្រិដ្ឋកម្មរួម II មានព្រះរាជ

[88] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះស្តីពីសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ ៨៧ ដល់ ៨៨; សេចក្តីសម្រេចលើភាពអាចទទួលយកបាននូវសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ ៣៨។

[89] សាស្ត្រាចារ្យ Boot បានធ្វើការកត់សម្គាល់ថា ៖ "អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Tadić* ... បានប្រកាន់យកទស្សនៈថា 'ទស្សនទាននៃផែនការរួមដែលជាទម្រង់មួយនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនសមគំនិត ត្រូវបានបង្កើតឡើងយ៉ាងរឹងមាំនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ'។ សេចក្តីសន្និដ្ឋាននេះហាក់ដូចជាមិនត្រឹមត្រូវសោះ។ អ្វីដែលអាចចោទសួរបាននោះគឺថាតើយើងអាចលើកឡើងថា គោលការណ៍ទូទៅមួយនេះនៃច្បាប់ព្រហ្មទណ្ឌ គឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិបានដែរ ឬទេ ដោយផ្អែកលើតែរឿងក្តីពីរ ឬបីករណីតែប៉ុណ្ណោះនោះ"។ ឯកសាររបស់ MACHTELD BOOT ស្តីពីគោលការណ៍គ្មានបទល្មើស បើគ្មានច្បាប់ និងស្តីពីបញ្ហាយុត្តាធិការរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ ៖ អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម (Intersentia, ឆ្នាំ ២០០២), កថាខណ្ឌ ២៧៥។ *សូមមើល ដូចខាងលើ*, កថាខណ្ឌ ២៨២ ៖ "ការអង្កេតទាំងអស់នេះអាចឲ្យធ្វើការសន្និដ្ឋានថា អង្គជំនុំជម្រះតុលាការកំពូលបានរំលោភលើគោលការណ៍ *គ្មានបទល្មើស បើគ្មានច្បាប់ចែង* នៅក្នុងរឿងក្តីនេះ"។ អង្គបុរេជំនុំជម្រះបានសំអាងលើករណីបន្ថែមចំនួនពីរដែលមានលក្ខណៈមិនគ្រប់គ្រាន់ដើម្បីជួសជុលភាពខ្វះចន្លោះនោះនៅក្នុងរឿងក្តី *Tadić* បានទេ។ *សូមមើល* សេចក្តីសម្រេចលើសហឧក្រិដ្ឋកម្មរួមរបស់អង្គបុរេជំនុំជម្រះ, កថាខណ្ឌ ៦៥។

[90] យោងតាម Gideon Boas, នេះ"គឺជាការវិភាគករណីរបស់ *Tadić* ដែលប្រហែលជាមានចរិតលក្ខណៈដ៏គួរឲ្យបារម្ភបំផុត" BOAS, ទំព័រ ២១។ *សូមមើលផងដែរសំណុំរឿង កាំង ហ្កេកអ៊ាវ "ឌុច"*, ០០១/១៨-០៧-២០០៧-អវតក-កសចស (អបជ ០២), Kai Ambos, *សារណារបស់អ្នកដែលមិនមែនភាគីនៃរឿងក្តី* ពាក់ព័ន្ធនឹងសំណុំរឿងព្រហ្មទណ្ឌ លេខ០០១/១៨-០៧-២០០៧-អវតក-កសចស (អបជ ០២), ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៨, ឯកសារ D99/3/27, ទំព័រ ២៣ ៖ "ដំណោះស្រាយនៃរឿងក្តី *Tadić* ចំពោះច្បាប់យុត្តិសាស្ត្រសង្គ្រាមលោកលើកទី II យ៉ាងហោចណាស់មាន 'តម្លៃដែលបានអនុវត្តពីមុនមកមិនច្បាស់លាស់'; Attila Bogdan, *Individual Criminal Responsibility in the Execution of a "Joint Criminal Enterprise" in the Jurisprudence of the* ad hoc *International Tribunal for the Former Yugoslavia*, 6 INT'L CRIM. L. REV. 63, 109-12 (2006) ("Bogdan")។

ដីកាអង់គ្លេសមួយ និងករណីអាមេរិកមួយ[91]។ ដោយមិនធ្វើការដកច្បាប់យុទ្ធសាស្ត្រចេញពីយុត្តាធិការច្បាប់ស៊ីវិលនោះ ករណី និងយុត្តាធិការដែលបានពិនិត្យ ដោយមិនដក មានចំនួនតិចយ៉ាងខ្លាំងរហូតដល់មិនអាចបង្ហាញពីការអនុវត្តរបស់រដ្ឋ ឬសច្ចធារណ៍ធម្មានុរូប (*opinio juris*)[92]។ ជាងនេះទៀត រដ្ឋជាច្រើន រួមទាំងប្រទេសកម្ពុជាផង អនុវត្តសហចារីកម្ម មិនមែនការទទួលខុសត្រូវខាងសហឧក្រិដ្ឋកម្មរួមទេ[93]។

33. មាត្រា ២៥ នៃលក្ខន្តិកៈតុលាការឧក្រិដ្ឋកម្មអន្តរជាតិ,[94] ដែលបានកំណត់ទម្រង់នៃការទទួលខុសត្រូវឧក្រិដ្ឋកម្មជាបុគ្គល មិនបញ្ចូលទ្រឹស្តីសហឧក្រិដ្ឋកម្មរួម ក្នុងរឿងក្តី *Tadić* ទេ។ អង្គបុរេជំនុំជម្រះរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិបានច្រានចោលពាក្យសុំដាក់ទម្រង់សហឧក្រិដ្ឋកម្មរួម ប៉ុន្តែគាំទ្រដល់សហចារី

---

[91] *សូមមើល រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Tadić, ឯកសារ IT-94-1-A, សាលដីកា, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ ("សាលដីកាលើករណីរបស់ *Tadić*"), កថាខណ្ឌ ២០២។ *សូមមើលផងដែរសំណុំរឿង កាំង ហ្គេចអ៊ាវ ហៅ "ឌុច"*, សំណុំរឿង ០០១/១៨-០៧-២០០៧-អវតក-កសចស (អបជ ០២), សារណារបស់អ្នកមិនមែនជាភាគីក្នុងរឿងក្តីដែលដាក់ជូនដោយមជ្ឈមណ្ឌលដើម្បីសិទ្ធិមនុស្ស និងពហុច្បាប់, សាកលវិទ្យាល័យ McGill, ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៨, ឯកសារ D99/3/25, កថាខណ្ឌ ២២, ទាក់ទងនឹងករណីបន្ថែមដែលបានដកស្រង់។

[92] *សូមមើល* Bogdan, ទំព័រ ១១០ ៖ "សាលក្រមនេះក៏ខកខានមិនបានពិនិត្យ *គោលការសច្ចធារណ៍ធម្មានុរូប (opinio juris)*, ដោយចាត់ទុកថា 'គោលនយោបាយ និងសេចក្តីប្រកាសរបស់រដ្ឋថាជាបង្ហាញពីការប្តេជ្ញារបស់ជាតិ'"។

[93] *សូមមើល* ក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦, មាត្រា ៨៣។ យោងតាមវិទ្យាស្ថាន Max Planck រដ្ឋភាគច្រើនបំផុតប្រើប្រាស់សហចារីកម្ម ជាជាងសហឧក្រិដ្ឋកម្មរួម។ *សូមមើល ការចូលរួមក្នុងឧក្រិដ្ឋកម្ម: ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អ្នកដឹកនាំ នៅក្នុងក្រុម និងបណ្តាញឧក្រិដ្ឋជន ទស្សនរបស់អ្នកជំនាញ ដែលកំណត់ដោយអង្គការសហប្រជាជាតិ តុលាការ* ICTY, ការិយាល័យសម្របសម្រួលគម្រោងរដ្ឋអាជ្ញា (Office of the Prosecutor Project Coordination): សាស្ត្រាចារ្យបណ្ឌិត Ulrich Sieber, Priv. Doz. Dr. Hans Georg Koch, Jan Michael Simon, Max Planck Institutfürausländisches und internationalesStrafrecht, Freiburg, អាល្លឺម៉ង់, ភាគ ១ ៖ ការវិភាគបែបប្រៀបធៀបនៃប្រព័ន្ធច្បាប់, ទំព័រ ១៦។ សហចារីកម្មបង្ហាញពីភាពផ្សេងគ្នារវាងការទទួលខុសត្រូវស្នូល និងបន្ទាប់បន្សំ ដែលជាការចាំបាច់នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល "ពីព្រោះតែភាពខុសគ្នានៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលក្នុងការកំណត់ទោសអតិបរមា ចំពោះបុគ្គលម្នាក់ដែលគ្រាន់តែជួយ និងទំនុកបម្រុងមេខ្លោង" Ciara Damgaard, *The Joint Criminal Enterprise Doctrine: A "Monster Theory of Liability" or a Legitimate and Satisfactory Tool in the Prosecution of the Perpetrators of Core International Crimes? in* INDIVIDUAL CRIMINAL RESPONSIBILITY FOR CORE INTERNATIONAL CRIMES 129, 194 (Springer 2008).

[94] លក្ខន្តិកៈនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិត្រូវបានធ្វើសេចក្តីព្រាងដោយមានការចរចាយ៉ាងទូលំទូលាយអស់រយៈពេលជាង ៣ ឆ្នាំ និងមានការចូលរួមពីប្រទេសចំនួន ១៦០។ John Washburn, *The Negotiation of the Rome Statute for the International Criminal Court and International Lawmaking in the 21st Century*, 11 PACE INT'L L. REV. 361 (1999)។ *សូមមើល* សាលដីកាលើករណីរបស់ *Tadić*, កថាខណ្ឌ ២២៣។

កម្ម[95]។ ដោយពិចារណាឃើញថា **ក.**ប្រព័ន្ធច្បាប់ភាគច្រើនបំផុតមិនអនុវត្តសហឧក្រិដ្ឋកម្មរួម **ខ.**លក្ខន្តិកៈនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិពុំមានចែងពីសហឧក្រិដ្ឋកម្មរួម និង **គ.**អង្គជំនុំជម្រះនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិបានច្រានចោលការអនុវត្តសហឧក្រិដ្ឋកម្មរួមនោះ សហឧក្រិដ្ឋកម្មរួមនេះពិតណាស់មិនមែនជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ *នៅពេលបច្ចុប្បន្ននេះឡើយ* កុំថាឡើយក្នុងរយៈពេល ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ សហឧក្រិដ្ឋកម្មរួម I និងសហឧក្រិដ្ឋកម្មរួម II មិនអាចយកមកអនុវត្ត នៅ អ.វ.ត.ក បានឡើយ។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងសម្រេចថា សហឧក្រិដ្ឋកម្មរួម I និង/ឬសហឧក្រិដ្ឋកម្មរួម II អាចយកមកអនុវត្តនោះ មេធាវីការពារក្តីសូមដាក់ចំណុចដូចខាងក្រោមទាក់ទងនឹងធាតុផ្សំទាំងពីរនេះ។

### ២. ធាតុផ្សំនៃទម្រង់មូលដ្ឋាននៃសហឧក្រិដ្ឋកម្មរួម (JCE I) និងទម្រង់ជាប្រព័ន្ធ នៃសហឧក្រិដ្ឋកម្មរួម (JCE II)

34. ធាតុផ្សំនៃ JCE I និង JCE II កើតមានឡើងនៅពេលដែល ៖ ក. មានមនុស្សច្រើន ខ. មានគោលបំណងឧក្រិដ្ឋរួម និង គ. ជនជាប់ចោទជួយ និងទំនុកបម្រុងយ៉ាងសំខាន់នៅក្នុងគោលបំណងឧក្រិដ្ឋរួមនោះ[96]។ ក្រោម JCE I ជនជាប់ចោទត្រូវតែមានចេតនាប្រព្រឹត្តបទឧក្រិដ្ឋជាមួយនឹងសហចារីរបស់គាត់[97]។ ក្រោម JCE II ដែលពាក់ព័ន្ធជាពិសេសនឹង "ប្រព័ន្ធធ្វើបាបដែលត្រូវបានគេព្រមព្រៀង

---

[95] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Lubanga Dyilo, ឯកសារ ICC-01/04-01/06, សេចក្តីសម្រេចលើការបញ្ជាក់ពីការចោទប្រកាន់, ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៧, កថាខណ្ឌ ៣២៧ ដល់ ៣០ កថាខណ្ឌ ៣៣៣; *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Katanga & Ngudjolo, ឯកសារ ICC-01/04-01/07, សេចក្តីសម្រេចលើការបញ្ជាក់ពីការចោទប្រកាន់, ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៨, កថាខណ្ឌ ៤៨៤ ដល់ ៨៥។ *សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Lubanga Dyilo, ICC-01/04-01/06, សាលក្រមអនុលោមតាមមាត្រា ៧៤ នៃលក្ខន្តិកៈ ដោយធ្វើការអនុវត្តសហចារីកម្ម មិនមែនការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួមទេ។

[96] សាលក្រមលើរឿងក្តី *ឌុច* កថាខណ្ឌ ៥០៨។

[97] ដូចយោងខាងលើ កថាខណ្ឌ ៥០៩។ ជនជាប់ចោទត្រូវតែមានចេតនាក្នុងការចូលរួមក្នុងផែនការរួម ដែលមានគោលបំណងប្រព្រឹត្តឧក្រិដ្ឋកម្ម។ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Kvočka,* IT-98-30/1-A សាលដីកា ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៥ ("សាលដីកាលើរឿងក្តី *Kvočka* Appeals ") កថាខណ្ឌ ៨២។ សាលដីកាលើរឿងក្តី *Vasiljević* កថាខណ្ឌ ១០២។ សាលដីកាលើរឿងក្តី *Brđanin* កថាខណ្ឌ ៣៦៥។ ប្រសិនបើឧក្រិដ្ឋកម្មដែលមានចេតនាជាក់លាក់គឺជាចំណុចមួយដ៏សំខាន់បំផុត ដូចជាការធ្វើទុក្ខបុកម្នេញ នោះជនជាប់ចោទត្រូវតែមានចេតនានោះ។ សាលដីកាលើរឿងក្តី *Krnojelac* កថាខណ្ឌ ១១១។ សាលដីកាលើរឿងក្តី *Kvočka* កថាខណ្ឌ ១១០, ២៤០។ សាលក្រមលើរឿងក្តី *Popović* កថាខណ្ឌ ១០២២។ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Simba,* ICTR-01-76-T សាលក្រម ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៥ កថាខណ្ឌ ៣៨៧។

ជារួម"[98] ជនជាប់ចោទត្រូវតែ "បានដឹងអំពីចរិតលក្ខណៈនៃប្រព័ន្ធ" និងមានចេតនាជួយជ្រោមជ្រែងប្រព័ន្ធធ្វើបាបជារួមនេះ[99]។ ជនជាប់ចោទត្រូវតែដឹង*ដោយខ្លួនឯងផ្ទាល់*អំពីប្រព័ន្ធធ្វើបាប[100]។ អង្គជំនុំជម្រះសាលាដំបូងអាចរកឃើញត្រឹមតែថា ជនជាប់ចោទមានចេតនាដែលជាធាតុផ្សំចាំបាច់ ប្រសិនបើវាជាការសន្និដ្ឋានដ៏សមហេតុផលតែមួយគត់ចេញពីភ័ស្តុតាង[101]។

35. ដើម្បីឱ្យសមាជិក JCE ទទួលខុសត្រូវចំពោះអំពើរបស់អ្នកដែលមិនមែនជាសមាជិកនោះ ឧក្រិដ្ឋកម្មត្រូវតែជាប់ពាក់ព័ន្ធនឹងសមាជិក JCE[102]។ សមាជិក JCE ត្រូវតែបានប្រព្រឹត្តអនុលោមតាមគោលបំណងរួម នៅពេលដែលគាត់បានប្រើអ្នកដែលមិនមែនជាសមាជិកឱ្យប្រព្រឹត្តអំពើពិរុទ្ធ (*actus reus*) នៃឧក្រិដ្ឋកម្ម[103]។ ដើម្បីកំណត់អំពីភាពទទួលខុសត្រូវរបស់សមាជិក JCE ចំពោះអំពើរបស់ចារីដែលមិនមែនជាសមាជិកនោះ ការអង្កេតដ៏សំខាន់បំផុត គឺអំពើ និងសភាពផ្លូវចិត្តរបស់សមាជិក JCE មិនមែនចេតនាឧក្រិដ្ឋ (mens rea) របស់អ្នកដែលមិនមែនជាសមាជិកឡើយ[104]។

### ឆ. ការទទួលខុសត្រូវរបស់អ្នកបញ្ជា

36. ការទទួលខុសត្រូវរបស់អ្នកបញ្ជា រួមទាំងការទទួលខុសត្រូវរបស់ថ្នាក់លើជាជនស៊ីវិល មិនអាចយកមកអនុវត្តបានទេនៅ អ.វ.ត.ក[105]៖ ក. ការយកការទទួលខុសត្រូវរបស់អ្នកបញ្ជាមកអនុវត្តនៅក្នុង

---

[98] សាលក្រមលើរឿងក្តី ឌុច កថាខណ្ឌ ៥០៩។

[99] ដូចយោងខាងលើ។

[100] សាលដីកាលើរឿងក្តី *Vasiljević* កថាខណ្ឌ ១០១។ សូមមើល សាលដីកាលើរឿងក្តី *Kvočka* កថាខណ្ឌ ១១៨។ សាលដីកាលើរឿងក្តី *Krnojelac* កថាខណ្ឌ ៩៧។

[101] សាលដីកាលើរឿងក្តី *Brđanin* កថាខណ្ឌ ៤២៩។

[102] ដូចយោងខាងលើ កថាខណ្ឌ ៤១៣។ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Karemera និងអ្នកផ្សេងទៀត* ICTR-98-44-T សាលក្រម ចុះថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ១៤៤០។

[103] សាលដីកាលើរឿងក្តី *Brđanin* កថាខណ្ឌ ៤១៣។ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Krajišnik*, IT-00-39-A សាលដីកា ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៩ កថាខណ្ឌ ២២៦។

[104] សូមមើលរឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Sesay និងអ្នកផ្សេងទៀត* SCSL-04-15-A សាលដីកា ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៩ កថាខណ្ឌ ៦៥៣។ សូមមើលផងដែរ ដូចយោងខាងលើ កថាខណ្ឌ ៤០០។

[105] សូមមើល សំណើប្រឆាំងនឹងការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើ កថាខណ្ឌ ៥-២០។ ជម្រើសមួយសំណើសុំស្តីពីការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើ កថាខណ្ឌ ៥-២១។ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស ស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើ កថាខណ្ឌ ២៩-៥៦។ ការឆ្លើយតបជាលាយលក្ខណ៍អក្សរដោយមានថែងសេចក្តីសន្និដ្ឋានផ្ទាល់មាត់ កថាខណ្ឌ ២១-៣២។ ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១២៧-៤៣។ បណ្តឹងឧទ្ធរណ៍ប្រឆាំង

រឿងក្តីមួយចំនួនក្រោយសង្គ្រាមលោកលើកទី II មិនគ្រប់គ្រាន់ដើម្បីបង្កើតនូវឋានៈទំនៀមទម្លាប់ឡើយ[106] ខ. ការអនុវត្តរបស់រដ្ឋក្នុងឆ្នាំ ១៩៧៥-៧៩ មិនមានលក្ខណៈទូទៅ ឬមានសង្គតិភាព គ្រប់គ្រាន់ដើម្បីបង្កើតបានជាបទដ្ឋាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ទាក់ទិននឹងការទទួលខុសត្រូវរបស់អ្នកបញ្ជាទេ[107] និង គ. ពិធីសារបន្ថែមទី I ពុំបានយកច្បាប់ទំនៀមទម្លាប់អន្តរជាតិមកចងក្រងជាច្បាប់ឡើយ ទាក់ទិននឹងបញ្ហានេះ[108]។ អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសម្រេចថា ការទទួលខុសត្រូវរបស់អ្នកបញ្ជា យកមកអនុវត្តនៅ អ.វ.ត.ក[109] ហើយអង្គជំនុំជម្រះសាលាដំបូងមានកំហុស ក្នុងការយកការទទួលខុសត្រូវរបស់អ្នកបញ្ជាមកអនុវត្តជាទម្រង់នៃការទទួលខុសត្រូវ[110]។

### ១. អត្ថិភាពនៃការទទួលខុសត្រូវរបស់អ្នកបញ្ជាក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងឆ្នាំ ១៩៧៥-៧៩

37. ទោះបីជាការជំនុំជម្រះក្តីមួយចំនួនក្រោយសង្គ្រាមលោកលើកទី II យកសញ្ញាណនៃការទទួលខុស ត្រូវរបស់អ្នកបញ្ជាមកអនុវត្តជាទម្រង់នៃការទទួលខុសត្រូវយ៉ាងណាក៏ដោយ ក៏ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង ធម្មនុញ្ញរបស់ IMT និងធម្មនុញ្ញរបស់ IMTFE ពុំមានបទបញ្ញត្តិចែងអំពីទម្រង់នៃការទទួលខុសត្រូវនេះឡើយ[111]។ លើសពីនេះទៀត "ច្បាប់យុត្តិសាស្ត្រក្រោយសង្គ្រាម លោកលើកទី II ពុំមានសង្គតិភាពនៅក្នុងការធ្វើសេចក្តីសម្រេចឡើយ ពាក់ព័ន្ធនឹងលក្ខណៈនៃការទទួលខុសត្រូវ

---

នឹងដីកាដំណោះស្រាយ កថាខណ្ឌ ២៨៣-៣២២។ សារណាឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១១៤-៣៣។ ចម្លើយតបចំពោះការឆ្លើយតបរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី *Advocats Sans Frontières* ទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២០-២៤។ សេចក្តីសង្ខេបអញ្ញត្រកម្ម កថាខណ្ឌ ២៦។

[106] សូមមើល សារណា កថាខណ្ឌ ៤ សម្រាប់និយមន័យនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

[107] សូមមើល *North Sea Continental Shelf* កថាខណ្ឌ ៧៤។ *Military and Paramilitary Activities* កថាខណ្ឌ ២០៧។

[108] ពិធីសារបន្ថែមទី I អាចមិនត្រូវបានយកមកធ្វើជាសំអាងសម្រាប់អ្វីមួយឡើយ ក្រៅតែពីសក្តានុពលនៃពិធីសារនេះ ដើម្បីបញ្ជាក់អំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ពិធីសារបន្ថែមទី I ត្រូវបានប្រទេសកម្ពុជាផ្តល់សច្ចាប័ននៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ ១៩៩៨ ប៉ុណ្ណោះ។

[109] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៤៥៨-៦០។

[110] សូមមើល សាលក្រមលើរឿងក្តី ឌុច កថាខណ្ឌ ៥៣៨-៤៧។

[111] សូមមើល Mirjam Damaska, *The Shadow Side of Command Responsibility*, 49 AM. J. COMP. L. 455, 485 (2001) (“Damaska”).

ដែលកើតចេញពីទស្សនទាននៃការទទួលខុសត្រូវរបស់អ្នកបញ្ជា”[112]។ ក្នុងឆ្នាំ ១៩៧៥-៧៩ រដ្ឋភាគច្រើន រួមទាំងកម្ពុជាផងដែរ ពុំមានបទបញ្ញត្តិជាក់លាក់ចែងអំពីការទទួលខុសត្រូវរបស់អ្នក បញ្ជានៅក្នុងក្រមព្រហ្មទណ្ឌរបស់រដ្ឋទាំងនោះឡើយ[113]។ នៅពេលដែលក្រមព្រហ្មទណ្ឌជាតិពុំមាន ចែងអំពីបទបញ្ញត្តិបែបនេះ បទបញ្ញត្តិបែបនេះមិនមានសង្គតិភាពគ្រប់គ្រាន់ឡើយសម្រាប់ជា មូលដ្ឋាននៃការអនុវត្តរបស់

---

[112] រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Halilović*, IT-01-48-T សាលក្រម ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៥ (“សាលក្រមលើរឿងក្តី *Halilović*”) កថាខណ្ឌ ៤៨ (សេចក្តីបញ្ជាក់បន្ថែម)។ កង្វះខាតនូវភាពច្បាស់លាស់នេះនាំឲ្យគណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិប្រកាន់យកជំហរមួយនៅឆ្នាំ ១៩៤៩ ថា “គោលការណ៍ដែលគ្រប់គ្រង [ការទទួលខុសត្រូវរបស់អ្នកបញ្ជា] ... មិនទាន់បានដោះស្រាយនៅឡើយទេ”។ សូមមើល Kai Ambos ការទទួលខុសត្រូវរបស់ថ្នាក់លើ នៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ៖ សេចក្តីអត្ថាធិប្បាយ វ៉ុល I 823, 831 (OUP 2002)។ សាស្ត្រាចារ្យ Martinez បានបញ្ជាក់ថា៖ “កំហុសឆ្គងដែលសំខាន់បំផុត [នៃរឿងក្តីក្រោយសង្គ្រាមលោកលើកទីII ទាំងនេះ] គឺថា វាបង្ហាញនូវទិដ្ឋភាពជាច្រើនដែលមិនស៊ីសង្វាក់គ្នា ស្តីពីកត្តាផ្លូវចិត្តដែលជាលក្ខខណ្ឌចាំបាច់សម្រាប់ឲ្យមានទំនួលខុសត្រូវ តែជាអកុសល ជួនកាលកំហុសឆ្គងនោះកើតមាននៅក្នុងសេចក្តីសម្រេចតែមួយក៏មាន... ដែលរឿងក្តីទាំងនោះបានបង្ហាញជាមុននូវការភ័ន្តច្រឡំដែលមានជាប់មកជាមួយទ្រឹស្តីនៅតុលាការ ICTY និង តុលាការ ICTR”។ សូមអានអត្ថបទរបស់ Jenny S. Martinez, *ការយល់ដឹងពីធាតុអត្តនោម័តនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ចាប់ពី Yamashita ដល់ Blaškić និងក្រោយពីនោះទៀត* 53 J. Int’l Crim. Just. 638, 640 (2007) (“Martinez”)។ សូមមើលផងដែរ ជម្រើសមួយសំណើសុំស្តីពីការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើ ឧបសម្ព័ន្ធសម្រាប់ការពិភាក្សាអំពីថាតើធាតុផ្សំអត្តនោម័តត្រូវបានយកមកអនុវត្ត យ៉ាងដូចម្តេចនៅតុលាការ *មិនអចិន្ត្រៃយ៍*។ សូមមើលសៀវភៅ និពន្ធដោយ Curt A. Hessler មានចំណងជើងថា ការទទួលខុសត្រូវរបស់អ្នកបញ្ជាសម្រាប់ឧក្រិដ្ឋកម្មសង្គ្រាម (*Command Responsibility for War Crimes*), 82 Yale L. J. 1274, 1281 (1972-1973)។

[113] សាស្ត្រាចារ្យ Damaska ពន្យល់ថា “[បញ្ញត្តិស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើនៃលក្ខន្តិកៈរបស់តុលាការ ICTY] បានពង្រីកព្រំដែននៃទំនួលខុសត្រូវ នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ហួសពីការកំណត់ដែលបង្កើតឡើងដោយប្រព័ន្ធច្បាប់ជាតិ...។ អាស្រ័យហេតុនេះ មូលដ្ឋាននៃទំនួលខុសត្រូវក្នុងកថាខណ្ឌនេះ មិនបានចូលរួមក្នុងប្រភេទជាលក្ខណៈប្រពៃណីនៃច្បាប់ក្នុងស្រុកទេ៖ ក៏ប៉ុន្តែមេដឹកនាំត្រូវទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋកម្មរបស់អ្នកក្រោមបង្គាប់របស់ខ្លួន ស្តីពីមូលដ្ឋានដែលមានភាពតឹងរ៉ឹង និងគួរឲ្យចាប់អារម្មណ៍ជាងមុន គឺការខកខានមិនបានទប់ស្កាត់ និងការខកខានមិនបានដាក់ទណ្ឌកម្ម។ *ករណីទាំងពីរនេះ បែកចេញជាចំណែកដែលមានភាពលំបាកនឹងសម្រួលចូលគ្នាជាមួយគោលការណ៍ ដែលបញ្ជាក់ពីច្បាប់ព្រហ្មទណ្ឌក្នុងស្រុក*”។ អត្ថបទរបស់ Damaska ទំព័រ៤៦១ (គូសបញ្ជាក់បន្ថែម)។ សូមមើលផងដែរ មូលដ្ឋានទិន្នន័យនៃការអនុវត្តន៍ច្បាប់ជាតិ នៅលើគេហទំព័ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (National Implementing Legislation Database on the ICC website) ដែលមានបង្ហាញពីតារាងនៃប្រទេសមួយចំនួនតូចដែលបង្កើតជាច្បាប់សម្រាប់អនុវត្តទៅការទទួលខុសត្រូវរបស់ថ្នាក់លើ។ *អាចរកបាននៅឯគេហទំព័រ* http://iccdb.webfactional.com/data/keyword/569/។

រដ្ឋដែលមានភាពស៊ីសង្វាក់គ្នា និងទូទៅ ដែលជាតម្រូវការសម្រាប់ច្បាប់ ទំនៀមទម្លាប់អន្តរជាតិ[114]។ មានភ័ស្តុតាងតិចតួចបង្ហាញថា រដ្ឋភាគច្រើនបានដាក់បញ្ចូល និងយកបទបញ្ញត្តិនៃការទទួលខុសត្រូវរបស់អ្នកបញ្ជាមកអនុវត្តនៅក្នុងច្បាប់ជាតិ របស់រដ្ឋទាំងនោះនៅក្នុងឆ្នាំ ១៩៧៥-៧៩ ឬក៏មានភ័ស្តុតាងតិចតួចបង្ហាញថា ធាតុផ្សំនៃការទទួលខុសត្រូវរបស់អ្នកបញ្ជាត្រូវបានយកមកអនុវត្តយ៉ាងស៊ីសង្វាក់គ្នានៅក្នុងរដ្ឋ និងរវាងរដ្ឋនិងរដ្ឋ នៅពេលយកមកអនុវត្តនោះ[115]។

38. ការទទួលខុសត្រូវរបស់អ្នកបញ្ជាមិនត្រូវបានចងក្រងជាច្បាប់ឡើយ នៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ ឬពិធីសារបន្ថែមទី I។ ពិធីសារបន្ថែមទី I ចូលជាធរមាននៅថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ១៩៧៧។ មាត្រា ៨៦ និង ៨៧ ដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់អ្នកបញ្ជានៅក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិ[116] កំណត់ជាលើកដំបូងថា ច្បាប់អន្តរជាតិបានដាក់ទោសព្រហ្មទណ្ឌទៅលើថ្នាក់លើចំពោះការខកខានមិនបានធ្វើចំណាត់ការ។ ធាតុផ្សំទាក់ទងនឹងការដឹងដែលបង្កឲ្យមានទោសនៅក្នុងមាត្រា ៨៦ ត្រូវបានធ្វើសេចក្តីព្រាងឡើងវិញចំនួនប្រាំដង មុននឹងដាក់ឲ្យធ្វើវិសោធនកម្មបន្ថែមទៀត[117] ដែល

---

[114] ដូចដែល បណ្ឌិត Ferdinandusse កត់សម្គាល់៖ "ការកំណត់និយមន័យនៃបទឧក្រិដ្ឋកម្មអន្តរជាតិ នៅថ្នាក់ជាតិ តែងតែមានភាពមិនពេញលេញ ឬ លើសលស់អត្ថន័យ ឬ មានទាំងពីរករណីតែម្តង ...។ ភាពមិនស៊ីសង្វាក់បែបនេះ ក៏ត្រូវបានរកឃើញផងដែរនៅក្នុងការកំណត់និយមន័យនៅថ្នាក់ជាតិចំពោះ ... ជាបញ្ហាបន្ទាប់បន្សំដូចការទទួលខុសត្រូវរបស់ថ្នាក់លើ"។ សូមអាន WARD N. FERDINANDUSSE, DIRECT APPLICATION OF INTERNATIONAL CRIMINAL LAW IN NATIONAL COURTS 118-19 (T.M.C. Asser Press 2006)។

[115] បើតាមទស្សនៈរបស់សាស្ត្រាចារ្យ Bantekas គឺថា ក្រោយសង្គ្រាមលោកលើកទី II មាន "ការធ្លាក់ចុះនៃការប្រើប្រាស់ទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើរយៈពេលជាង ៣០ ឆ្នាំ។ ក្នុងអំឡុងពេលនេះ ដោយមានការជំរុញពីផ្នែកនយោបាយក្នុងការអនុវត្តបទចោទប្រកាន់បែបនេះផងនោះ វេទិកាថ្នាក់ជាតិមានភាពស្ទាក់ស្ទើរក្នុងការដាក់ទោសទណ្ឌដល់មន្ត្រីណាម្នាក់ ចំពោះបទឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ដោយអ្នកនៅក្រោមបង្គាប់របស់ខ្លួន ...។ ជាងនេះទៅទៀត *គ្មានការយល់ស្របគ្នាជាឯកច្ឆន្ទ ទាក់ទងនឹងចេតនាឧក្រិដ្ឋសមស្រប ដែលបានសម្រេចដោយសហគមន៍អន្តរជាតិឡើយ*"។ អត្ថបទរបស់ Ilias Bantekas, *ច្បាប់ស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើនាសម័យទំនើប* *(Contemporary Law of Superior Responsibility)* 93 AM. J. INT'L L. 573, 574-75 (ឆ្នាំ១៩៩៩) ("អត្ថបទរបស់ Bantekas *ច្បាប់ស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើនាសម័យទំនើប*") (គូសបញ្ជាក់បន្ថែម)។

[116] ពិធីសារបន្ថែម I មាត្រា ៨៦(២), ៨៧(១), ៨៧(៣)។

[117] សូមមើលអត្ថបទរបស់ Bantekas, *ច្បាប់ស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើនាសម័យទំនើប (Contemporary Law of Superior Responsibility)* ត្រង់ទំព័រ ៥៩១។ តាមទស្សនៈរបស់សាស្ត្រាចារ្យ Martinez យល់ថា "ពិធីសារបន្ថែមទី I កាន់តែធ្វើឲ្យ*ធាតុអត្តនោម័ត*មានភាពមិនច្បាស់លាស់ថែមទៀត ដែលធាតុផ្សំនេះជាលក្ខខណ្ឌចាំបាច់នៃការទទួលខុសត្រូវរបស់ថ្នាក់លើ នៅក្នុងច្បាប់អន្តរជាតិ"។ អត្ថបទរបស់ Martinez, ទំព័រ ៦៥៣។ សេចក្តីអធិប្បាយចំពោះពិធីសារបន្ថែមទី I កត់សម្គាល់ថា មាត្រា ៨៦

បង្ហាញថា សំណៅចុងក្រោយត្រូវបានផ្អែកទៅលើការស្រុះស្រួលគ្នារវាងរដ្ឋនិងរដ្ឋ និងមិនចាំបាច់ត្រូវតែឆ្លុះបញ្ចាំងពីសភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ។

39. ដោយពិចារណាទៅលើការអនុវត្តរបស់រដ្ឋដែលមិនស៊ីសង្វាក់គ្នា ឬមានកង្វះខាត និងការខ្វែងយោបល់គ្នាចំពោះទ្រឹស្តីនេះ ដែលមានជាតឹកតាងស្រាប់តាមរយៈច្បាប់យុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី II ពិធីសារបន្ថែមទី I ពុំបានយកច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលមានស្រាប់ស្តីពីការទទួលខុសត្រូវរបស់អ្នកបញ្ជា មកចងក្រងជាច្បាប់ឡើយ។ នៅចុងឆ្នាំ ១៩៧៨ ទោះបីជារដ្ឋចំនួន ៥៤ បានចុះហត្ថលេខាលើពិធីសារបន្ថែមទី I (កម្ពុជាមិនស្ថិតនៅក្នុងចំណោម រដ្ឋទាំងនោះឡើយ) យ៉ាងណាក៏ដោយ[118] ក៏មានតែរដ្ឋចំនួន ៣ ប៉ុណ្ណោះ បានផ្តល់សច្ចាប័នលើពិធីសារបន្ថែមនេះ[119]។ ពិធីសារបន្ថែមទី I មានគោលបំណងដាក់កាតព្វកិច្ចលើរដ្ឋ មិនមែនលើ បុគ្គលឡើយ[120]។ វាមិនមែនជាបទដ្ឋាន

---

នៅក្នុងអត្ថបទជាភាសាអង់គ្លេស និងភាសាបារាំង ហាក់ដូចជាមានភាពខ្វែងគ្នាចំពោះលក្ខខណ្ឌនៃធាតុផ្សំចេតនាឧក្រិដ្ឋ នៃការទទួលខុសត្រូវរបស់ថ្នាក់លើ៖ "មានភាពផ្គាំផ្គងជាអន្លើៗរវាងអត្ថបទជាភាសាអង់គ្លេស '<u>ព័ត៌មានដែលគួរបានជួយឱ្យពួកគេអាចធ្វើការសន្និដ្ឋាន</u>" និងជាភាសាបារាំង '<u>des informations leur permettant de conclure</u>' ដែលមានន័យថា '<u>ព័ត៌មានដែលជួយឱ្យពួកគេអាចធ្វើការសន្និដ្ឋាន</u>'។ នៅក្នុងករណីនេះ វិធាននេះត្រូវអនុម័តតាមអត្ថន័យដែលសម្រួលល្អជាងគេចំពោះអត្ថបទដែលមានភាពខ្វែងគ្នានេះ ដោយយោងទៅកម្មវត្ថុ និងគោលបំណងរបស់សន្និសញ្ញា អាស្រ័យហេតុនេះ អត្ថបទជាភាសាបារាំងគួរតែមានអាទិភាព ដោយសារវាគ្របដណ្តប់ទៅលើករណីទាំងពីរនេះ"។ ពិធីសារបន្ថែមទី I សេចក្តីអត្ថាធិប្បាយ កថាខណ្ឌ ៣៥៤៥។

[118] *សូមមើល* តារាងរបស់ ICRC ស្តីពីរដ្ឋជាភាគី *ដែលអាចរកបាននៅគេហទំព័រ* http://www.icrc.org/ihl.nsf/WebSign?ReadForm&id=470&ps=P។

[119] រដ្ឋទាំងនោះមានដូចជា អែលសាល់វ៉ាឌ័រ, ហ្គាណា និង លីប៊ី។ ផ្ទុយទៅវិញ ក្នុងឆ្នាំ២០០១ អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Čelebići* បានពិចារណាលើមាត្រា ៨៧ នៃពិធីសារបន្ថែមទី I ដើម្បីឆ្លុះបញ្ចាំងពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចាប់ពីចុងឆ្នាំ១៩៩២មក ដែលមានរដ្ឋចំនួន១១៩ បានផ្តល់សច្ចាប័ន។ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Delalić* និងអ្នកផ្សេងទៀត IT- 96-21-A សាលដីកាចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០១ ("សាលដីកាលើរឿងក្តី *Čelebići*") ជើងទំព័រ ២៥១។

[120] *សូមមើល* ឧទាហរណ៍ មាត្រា ១, ៨៦, ៨៧, ៩១។ សេចក្តីអត្ថាធិប្បាយ ទំព័រ ២៥។ ដូចដែលសាស្ត្រាចារ្យ Ambos បានកត់សម្គាល់៖ "ទោះបីវិធានទាំងនេះត្រូវបានឆ្លើយតបជាបឋមចំពោះរដ្ឋជាភាគីក៏ដោយ ក៏បច្ចុប្បន្ននេះវិធានទាំងនេះត្រូវបានគេចាត់ទុកថាជាមូលដ្ឋាននៃវិធាននៃការទទួលខុសត្រូវចំពោះការខកខានរបស់បុគ្គលក្នុងការចាត់វិធានការ ចាប់តាំងពីពេលដែលទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ និងផ្នែកសំខាន់នៃបទល្មើសដែលបានបង្កើតឡើងដោយច្បាប់ក្រុងហ្សឺណែវ (រួមទាំងពិធីសារបន្ថែមទី I ផង) ត្រូវបានកំណត់ជា 'លក្ខណៈបុគ្គល" ដោយលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ និងដោយការអនុវត្តន៍នូវច្បាប់ជាតិ" (គូសបញ្ជាក់បន្ថែម)។ Kai Ambos, *សហឧក្រិដ្ឋកម្មរួម និង ការទទួលខុសត្រូវរបស់ថ្នាក់លើ (Joint Criminal Enterprise and Command Responsibility)* 5(1) J. INT'L CRIM. JUST. 1, 9 (ឆ្នាំ២០០៧)។

នៃច្បាប់អន្តរជាតិដែលបានប្រែក្លាយទៅជាច្បាប់ព្រហ្មទណ្ឌឡើយ ដែលបុគ្គលអាចត្រូវបានផ្តន្ទាទោស ប្រសិនបើរកឃើញថាមានពិរុទ្ធភាព[121]។ ពិធីសារបន្ថែមទី I មិនបានចង្អុលបង្ហាញនូវការអនុវត្តរបស់រដ្ឋដែលស៊ីសង្វាក់គ្នាជាទូទៅ ដែលចាំបាច់សម្រាប់កំណត់នូវអត្ថិភាពនៃការទទួលខុសត្រូវរបស់អ្នកបញ្ជានៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥-៧៩ ឡើយ។

40. នៅក្នុងឆ្នាំ ១៩៧៥-៧៩ ការទទួលខុសត្រូវរបស់អ្នកបញ្ជា មិនត្រូវបានកំណត់ឱ្យបានច្បាស់លាស់ជាទម្រង់នៃការទទួលខុសត្រូវ អនុលោមតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ។ លើសពីនេះទៀត ការទទួលខុសត្រូវរបស់អ្នកបញ្ជាមិនយកមកអនុវត្តចំពោះជម្លោះប្រដាប់អាវុធផ្ទៃក្នុង[122]

---

[121] សូមមើល រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Fofana និងអ្នកផ្សេងទៀត* SCSL-2004-14-AR72(E), សេចក្តីសម្រេចលើញត្តិបឋមដែលផ្អែកលើការខ្វះយុត្តាធិការ, យោបល់ជំទាស់របស់ចៅក្រម Robertson ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៤ កថាខណ្ឌ ១២។

[122] យុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី II និងពិធីសារបន្ថែមទី I ពាក់ព័ន្ធតែទៅនឹងជម្លោះប្រដាប់អាវុធអន្តរជាតិប៉ុណ្ណោះ។ ពិធីសារបន្ថែម II ដែលអាចអនុវត្តបានចំពោះជម្លោះប្រដាប់អាវុធផ្ទៃក្នុង ពុំមានចែងអំពីបទបញ្ញត្តិស្តីពីការទទួលខុសត្រូវរបស់អ្នកបញ្ជាឡើយ។ ទោះបីជាអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY យកការទទួលខុសត្រូវរបស់អ្នកបញ្ជាមកអនុវត្តចំពោះឧក្រិដ្ឋកម្មសង្គ្រាមនៅក្នុងជម្លោះប្រដាប់អាវុធផ្ទៃក្នុង (រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Hadžihasanović* និងអ្នកផ្សេងទៀត, IT-01-47-AR72, សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្គំ ជំទាស់ទៅនឹងយុត្តាធិការ ទាក់ទិននឹងការទទួលខុសត្រូវរបស់អ្នកបញ្ជា ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៣ ("សាលដីកាស្តីពីយុត្តាធិការលើរឿងក្តី *Hadžihasanović* ") កថាខណ្ឌ ២៩, ៣១) យ៉ាងណាក៏ដោយ ក៏សំអាងហេតុរបស់អង្គជំនុំជម្រះតុលាការកំពូលនេះមានវិការៈ។ ដូចដែលសាស្ត្រាចារ្យ van Schaack បានកត់សម្គាល់ អង្គជំនុំជម្រះតុលាការកំពូលបានមើលរំលងនូវមូលហេតុថាហេតុអ្វីបានជាអ្នកធ្វើសេចក្តីព្រាងពិធីសារបន្ថែមទី II មិនអាចកំណត់អំពីការទទួលខុសត្រូវរបស់អ្នកបញ្ជានៅក្នុងជម្លោះប្រដាប់អាវុធផ្ទៃក្នុង ឧទាហរណ៍ "ដោយពិចារណាទៅដល់ ទ្រឹស្តីដែលមិនអាចអនុវត្តបាននៅក្នុងជម្លោះបែបនេះ នៅពេលដែលកងកម្លាំងប្រដាប់អាវុធអាចនឹងគ្មានការគ្រប់គ្រងល្អ និងដាច់តែឯង ហើយអំណាចបញ្ជាអាចត្រូវបានប្រកាសដោយខ្លួនឯង តាមការអនុវត្តជាក់ស្តែង និងត្រូវបានធ្វើវិមជ្ឈការ"។ សូមអានអត្ថបទរបស់ Beth van Schaack, Crimen Sine Lege: *ច្បាប់បង្កើតដោយតុលាការនៅចំណុចប្រសព្វនៃច្បាប់ និងសីលធម៌* (Crimen Sine Lege: Judicial Lawmaking at the Intersection of Law and Morals), 97 Geo. L.J. 119, 166 (2008)។ អង្គជំនុំជម្រះតុលាការកំពូលក៏បានលើកបញ្ជាក់អំពីការអនុវត្តរបស់រដ្ឋបន្តិចបន្តួច ដោយទទួលស្គាល់ថា រដ្ឋភាគច្រើន "មិនមានចែងជាច្បាប់សម្រាប់ការទទួលខុសត្រូវរបស់ថ្នាក់លើ ស្មើគ្នាទៅនឹងថ្នាក់លើដែលមានការទទួលខុសត្រូវក្នុងជម្លោះផ្ទៃក្នុងទេ"។ សាលដីកាស្តីពីយុត្តាធិការលើរឿងក្តី *Hadžihasanović* កថាខណ្ឌ ១៧។ សូមមើលអត្ថបទរបស់ Christopher Greenwood, CMG, QC, *កំណត់សម្គាល់ និង សេចក្តីអធិប្បាយ៖ ការទទួលខុសត្រូវរបស់ថ្នាក់លើ និង សេចក្តីសម្រេចនៅក្នុងរឿងក្តី Hadžihasanović (Notes and Comments: Command Responsibility and the Hadžihasanović Decision)*, 2.2 J. INT'L CRIM. JUST. 598, 601 (ឆ្នាំ២០០៤)។

ឬចំពោះថ្នាក់លើជាជនស៊ីវិលឡើយ[123]។ ការទទួលខុសត្រូវរបស់អ្នកបញ្ជា រួមទាំងការទទួលខុសត្រូវរបស់ថ្នាក់លើជាជនស៊ីវិល មិនអាចយកមកអនុវត្តនៅ អ.វ.ត.ក បានទេ។

**២. ធាតុផ្សំនៃការទទួលខុសត្រូវរបស់អ្នកបញ្ជា**

41. ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងសម្រេចថា ការទទួលខុសត្រូវរបស់អ្នកបញ្ជាយកមកអនុវត្តជាទម្រង់នៃការទទួលខុសត្រូវនៅ អ.វ.ត.ក នោះ ធាតុផ្សំខាងក្រោមនេះត្រូវតែយកមកអនុវត្ត៖[124] ក. ថ្នាក់លើ*ស្របច្បាប់* ឬ*ជាក់ស្ដែង*[125] មានការគ្រប់គ្រងដ៏មានប្រសិទ្ធភាពទៅលើអ្នកនៅក្រោមបង្គាប់[126] ខ. ថ្នាក់លើបានដឹង[127] ឬមានហេតុផលដឹង[128] ថាអ្នកនៅក្រោមបង្គាប់អាចនឹងប្រព្រឹត្ត ឬបានប្រព្រឹត្ត

[123] *សូមមើល អត្ថបទរបស់* Martinez ទំព័រ ៦៣៨។ អត្ថបទរបស់ CHERIF BASSIOUNI, *សេចក្ដីផ្ដើមច្បាប់ព្រហ្មទណ្ឌអន្តរជាតិ (*INTRODUCTION TO INTERNATIONAL CRIMINAL LAW*)* ៣១៨, ៣២០ (Transnational Publishers ឆ្នាំ២០០៣)។ ពិធីសារបន្ថែមទី I និងទី II ពុំបានសំដៅទៅលើការទទួលខុសត្រូវរបស់អ្នកបញ្ជាជាជនស៊ីវិលឡើយ។ របាយការណ៍ចុងក្រោយរបស់គណៈកម្មការជំនាញស្ដីពីការទទួលខុសត្រូវរបស់ថ្នាក់លើ បានបញ្ជាក់ថា៖ "ករណីតាមច្បាប់ភាគច្រើនដែលពិចារណាទៅដល់ទ្រឹស្ដីនៃការទទួលខុសត្រូវរបស់ថ្នាក់លើនេះ គឺមានការពាក់ព័ន្ធទៅនឹងជនជាប់ចោទជាយោធា និងកងជីវពល"។ របាយការណ៍ចុងក្រោយរបស់គណៈកម្មការជំនាញ ដែលបង្កើតឡើងអនុលោមតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ៧៨០ (ឆ្នាំ១៩៩២) UN. Doc. S/1994/647 ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៩៤ ទំព័រ១៦។

[124] សូមមើល ច្បាប់ស្ដីពីការបង្កើតអ.វ.ត.ក មាត្រា ២៩។ សាលក្រមលើរឿងក្ដី ឌុច កថាខណ្ឌ ៥៣៨, ៥៤០-៤៧។

[125] សម្រាប់ការណែនាំទាក់ទិននឹងនិយមន័យនៃ ថ្នាក់លើ "ជាក់ស្ដែង" និង "ស្របច្បាប់" សូមមើល សាលដីកាលើរឿងក្ដី *Čelebići* កថាខណ្ឌ ១៩២-៩៣។ រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង *Nahimana* និងអ្នកផ្សេងទៀត ICTR-99-52-A, សាលដីកា ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ កថាខណ្ឌ ៤៨៤, ៧៨៧។

[126] សម្រាប់ការណែនាំទាក់ទិននឹងនិយមន័យនៃ "ការគ្រប់គ្រងដ៏មានប្រសិទ្ធភាព" សូមមើល សាលដីកាលើរឿងក្ដី *Čelebići* កថាខណ្ឌ ២៦៦។ សាលដីកាលើរឿងក្ដី *Blaškić* កថាខណ្ឌ ៦៩។ សាលដីកាលើរឿងក្ដី *Gacumbitsi* កថាខណ្ឌ ១៤៣។ រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង *Brima* និងអ្នកផ្សេងទៀត SCSL-2004-16-A, សាលដីកា ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៨ កថាខណ្ឌ ២៥៧។

[127] សម្រាប់ការណែនាំទាក់ទិននឹងនិយមន័យនៃ "បានដឹង" សូមមើលសាលដីកាលើរឿងក្ដី *Gacumbitsi* កថាខណ្ឌ ១៤៣។ រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង *Blaškić*, IT-95-14-T, សាលក្រម ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០០០ កថាខណ្ឌ ៣០៧-០៨។ រឿងក្ដីរដ្ឋ អាជ្ញា ទល់នឹង *Brima* និងអ្នកផ្សេងទៀត SCSL-04-16-T, សាលក្រម ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៧ ("សាលក្រមលើរឿងក្ដី*Brima*") កថាខណ្ឌ ៧៩២-៩៣។

[128] សម្រាប់ការណែនាំទាក់ទិននឹងនិយមន័យនៃ "មានហេតុផលដឹង" សូមមើល សាលដីកាលើរឿងក្ដី *Čelebići* កថាខណ្ឌ ២៣៨-៣៩, ២៤១។ សាលដីកាលើរឿងក្ដី *Blaškić* កថាខណ្ឌ ៦២-៦៣។ រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង *Hadžihasanović*, IT-01-47-A, សាលដីកា ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៨ ("សាលដីកាលើរឿងក្ដី *Hadžihasanović*") កថាខណ្ឌ ២៦១។ រឿងក្ដី រដ្ឋអាជ្ញា ទល់នឹង *Bagilishema*, ICTR-95-1A-A, សាលដីកា ចុះថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០០២ កថាខណ្ឌ ៤២។

ឧក្រិដ្ឋកម្ម និង គ. ថ្នាក់លើខកខានមិនបានចាត់វិធានការចាំបាច់ និងសមស្រប ដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្ម ឬដាក់ទណ្ឌកម្មចំពោះអ្នកដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មនោះ[129]។ ថ្នាក់លើទទួលខុសត្រូវតែចំពោះការខកខានមិនបានចាត់វិធានការនៅក្នុងអំណាចរបស់គាត់ប៉ុណ្ណោះ ដូចដែលបង្ហាញ តាមរយៈការគ្រប់គ្រងដ៏មានប្រសិទ្ធភាព ដែលគាត់មានទៅលើអ្នកនៅក្រោមបង្គាប់របស់គាត់[130] និង "សមត្ថកិច្ចពិតប្រាកដ" របស់គាត់ក្នុងការចាត់វិធានការ[131]។ ថ្នាក់លើទទួលខុសត្រូវ តែនៅ ពេលដែលឧក្រិដ្ឋកម្មបានកើតឡើង ដែលជាលទ្ធផលនៃអំពើអកម្មរបស់ថ្នាក់លើប៉ុណ្ណោះ[132]។ ថ្នាក់លើ ជា

---

[129] សម្រាប់ការណែនាំទាក់ទិននឹងនិយមន័យនៃវិធានការ "ចាំបាច់" និង "សមស្រប" សូមមើលសាលដីកាលើរឿងក្តី *Blaškić* កថាខណ្ឌ ៧២។ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Orić* IT-03-68-A, សាលដីកា ចុះថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០០៨ កថាខណ្ឌ ១៧៧។ សាលដីកាលើរឿងក្តី *Hadžihasanović* កថាខណ្ឌ ២៦០។ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Bagosora* និងអ្នកផ្សេងទៀត ICTR-98-41-A, សាលដីកា ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១ ("សាលដីកាលើរឿងក្តី *Bagosora*") កថាខណ្ឌ ៦៧២។ សាលក្រមលើរឿងក្តី *Brima* កថាខណ្ឌ ៧៩៨។

[130] សាលដីកាលើរឿងក្តី *Blaškić* កថាខណ្ឌ ៧២, ៤១៧។ សូមមើល ផងដែរ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Kayishema & Ruzindana* ICTR-95-1-A, សាលដីកា ចុះថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០១ ("សាលដីកាលើរឿងក្តី *Kayishema & Ruzindana* ") កថាខណ្ឌ ៣០២។ សាលដីកាលើរឿងក្តី *Bagosora* កថាខណ្ឌ ៦៨៣។ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Delalić* និងអ្នកផ្សេងទៀត IT- 96-21-T, សាលក្រម ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ("សាលក្រមលើរឿងក្តី *Čelebići*") កថាខណ្ឌ ៣៩៥។ សាលក្រម លើរឿងក្តី *Brima* កថាខណ្ឌ ៧៩៨។

[131] សាលដីកាលើរឿងក្តី *Kayishema & Ruzindana* កថាខណ្ឌ ៣០២។

[132] *សូមមើលរឿងក្តី សហរដ្ឋអាមេរិក ទល់នឹង* Wilhelm List *និងអ្នកផ្សេងទៀត* សវនាការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា Nürnberg ក្រោមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង វ៉ុល XI (1950) ("រឿងក្តី *Hostage Case*") ទំព័រ ៧៦។ សវនាការជំនុំជម្រះ *Franz Schonfeld* និងអ្នកផ្សេងទៀត, របាយការណ៍ច្បាប់អំពីការជំនុំជម្រះឧក្រិដ្ឋជន សង្គ្រាម គណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ វ៉ុល XI (1948) ទំព័រ ៧១។ យុត្តិសាស្ត្រក្រោយសង្គ្រាម លោកលើកទី II តម្រូវឱ្យមានទំនាក់ទំនងហេតុ និងផល។ សូមមើល ឧទាហរណ៍ រឿងក្តី *Hostage Case* ទំព័រ ១២៦១ ដែលតម្រូវឱ្យមាន " ភស្តុតាងនៃអំពើសកម្ម ឬអកម្មយ៉ាងច្បាស់ដែលមានទំនាក់ទំនងហេតុ និងផល ដែលចេតនាពិរុទ្ធអាច ត្រូវបានសន្និដ្ឋានចេញពីអំពើទាំងនោះ"។ សូមមើលផងដែរ ចៅក្រម Bernard របស់តុលាការ IMFTE ប្រទេសបារាំង៖ "ការទទួលខុសត្រូវចំពោះលទ្ធផលនៃអំពើអកម្ម គឺដាក់ទៅលើអ្នកប្រព្រឹត្តអំពើអកម្ម តែក្នុងករណីដែលការប្រព្រឹត្តនោះ គឺជាលទ្ធផលពិតប្រាកដរបស់អ្នកប្រព្រឹត្តអំពើអកម្មនោះប៉ុណ្ណោះ"។ រឿងក្តី *Schonfeld* និងអ្នកផ្សេងទៀត៖ "[ឧក្រិដ្ឋកម្មទាំងនោះ ត្រូវតែជា] លទ្ធផលធម្មតានៃការធ្វេសប្រហែសរបស់ជនជាប់ចោទ ឬនិយាយម្យ៉ាងវិញទៀតគឺថា ការណែនាំពី [ជនជាប់ចោទ] ដែលបានផ្តល់ក្នុងពេលវេលាមួយដែលសមរម្យ និងអាចទប់ស្កាត់ការសម្លាប់ក្រៅច្បាប់ណាមួយ មិនឱ្យកើតឡើងបាន" ដែលបានដកស្រង់ចេញពី GUÉNAËL METTRAUX, THE LAW OF COMMAND RESPONSIBILITY 84 (OUP 2009)។ លក្ខន្តិកៈរបស់តុលាការ ICC

ជនស៊ីវិលទទួលខុសត្រូវតែចំពោះអំពើអកម្មនៅពេលដែលពួកគេមានភារកិច្ច *នៅគ្រាដំបូង*ក្នុងការទប់ស្កាត់ ឬដាក់ទណ្ឌកម្មប៉ុណ្ណោះ[133]។ ការទទួលខុសត្រូវរបស់អ្នកបញ្ជាមិនយកមកអនុវត្តចំពោះឧក្រិដ្ឋកម្មដែលមានចេតនាជាក់លាក់ឡើយ[134]។

---

ក៏តម្រូវឲ្យមានទំនាក់ទំនងហេតុ និងផលផងដែរ។ លក្ខន្តិកៈរបស់តុលាការ ICC មាត្រា ២៨(ខ)(ii)។ ដោយពុំបានវិភាគលើយុត្តិសាស្ត្រដែលពាក់ព័ន្ធ ឬច្បាប់សន្ធិសញ្ញា អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Čelebići* បានបញ្ជាក់ថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនតម្រូវឲ្យបង្ហាញភ័ស្តុតាងទំនាក់ទំនងហេតុ និងផលរវាងការប្រព្រឹត្តរបស់ជនជាប់ចោទ និងបទឧក្រិដ្ឋដែលប្រព្រឹត្តដោយអ្នកក្រោមបង្គាប់នោះទេ។ សាលក្រមលើរឿងក្តី *Čelebići* កថាខណ្ឌ ៣៩៨។ សូមមើលអត្ថបទរបស់ Darryl Robinson មានចំណងជើងថា *How Command Responsibility Got So Complicated: A Culpability Contradiction, its Obfuscation, and a Simple Solution,* 13 MELB. J. INT'L L. 1, 25 (2012)។ សាលក្រមរបស់តុលាការ ICTY ក្រោយៗមកទៀត បានអនុម័តតាមសាលក្រមលើរឿងក្តី *Čelebići* ដោយពុំមានការវិភាគឯករាជ្យណាមួយឡើយ។ សូមមើលឧទាហរណ៍ សាលដីកាលើរឿងក្តី *Kordić & Čerkez* កថាខណ្ឌ ៨៣២។ សាលក្រមលើរឿងក្តី *Halilović* កថាខណ្ឌ ៧៨។ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Orić*, IT-03-68-T សាលក្រម ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៦ កថាខណ្ឌ ៣៣៨។ សាលក្រមលើរឿងក្តី *Brđanin* កថាខណ្ឌ ២៨០។

[133] សូមមើល អត្ថបទរបស់ Alexander Zahar, *ការទទួលខុសត្រូវរបស់ថ្នាក់លើដែលជាជនស៊ីវិល ចំពោះអំពើប្រល័យពូជសាសន៍* 14 Leiden J. Int'l L. 591, 603 (ឆ្នាំ២០០១)។ វាស្របគ្នាទៅនឹងគោលការណ៍ដែលថា "អំពើ អកម្មនឹងនាំឲ្យក្លាយជាទំនួលខុសត្រូវលុះត្រាតែ វាអាចនាំឲ្យមានការបង្កើតជាកាតព្វកិច្ចក្នុងការចាត់វិធានការប៉ុណ្ណោះ"[133] ដែលត្រូវបានទទួលស្គាល់នៅក្នុងមាត្រា ២៨(ខ)(ii) នៃលក្ខន្តិកៈរបស់តុលាការ ICC និងយុត្តិសាស្ត្រតុលាការ ICTY។ សូមមើលសាលក្រមលើរឿងក្តី *Čelebići* កថាខណ្ឌ ៣៣៤។

[134] ឧក្រិដ្ឋកម្មដែលមានចេតនាជាក់លាក់ ត្រូវតែបានប្រព្រឹត្តឡើងដោយមានចេតនាដែលជាធាតុផ្សំចាំបាច់។ សាលក្រមលើរឿងក្តី *ឌុច* កថាខណ្ឌ៣៧៩។ ទោះបីជាយ៉ាងណាក៏ដោយ ថ្នាក់លើ អាចនឹងមានទំនួលខុសត្រូវក្រោមការទទួលខុសត្រូវរបស់ អ្នកបញ្ជា នៅពេលដែលខ្លួនមិនមានចេតនាឲ្យបទឧក្រិដ្ឋមួយកើតឡើង និងអាចមិនបានដឹងថាអំពើនោះនឹងកើតឡើងទេ រហូតទាល់តែហេតុការណ៍នោះបានកើតឡើងរួចហើយ។ សូមមើលអត្ថបទរបស់ David L. Nersessian ដែលមានចំណងជើងថា *Whoops, I Committed Genocide! The Anomaly of Constructive Liability for Serious International Crimes*, 30 FLETCHER F. WORLD AFF. 81, 92-93 (2006)។